# កម្មវិធីពិភាក្សា
# និងផ្លាស់ប្តូរចំណេះដឹង

## ការលើកកម្ពស់វិស័យសេវាសាធារណៈ
## សម្រាប់ក្រុមងាយរងគ្រោះនៅកម្ពុជា

ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣
ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា



Australian Aid

ពន្លក ចំណេះ

The Asia Foundation

# កម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹង

## ការលើកកម្ពស់វិស័យសេវាសាធារណៈ សម្រាប់ក្រុមងាយរងគ្រោះនៅកម្ពុជា

ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣

ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា

Australian Aid

ពន្លក ចំណេះ

The Asia Foundation

# មាតិកា

សេចក្តីថ្លែងអំណរគុណ ........ i

អំពីអ្នករៀបចំកម្មវិធី ........ ii

សេចក្តីផ្តើម ........ ១

សុន្ទរកថាបើក ........ ៤

សុន្ទរកថាគន្លឹះ ........ ៧

កិច្ចពិភាក្សាបើកកម្មវិធី ........ ១០

ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដើម្បីជួយគាំទ្រដល់ក្រុមងាយរងគ្រោះនៅថ្នាក់ក្រោមជាតិ..១០

កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយស៖ ក្រុមងាយរងគ្រោះនៅកម្ពុជា ........ ១៤

ភាពធន់ និងការស្តារឡើងវិញ របស់បុគ្គលិកបម្រើការតាមសណ្ឋាគារនៅកម្ពុជា ........ ១៤

ការស្វែងយល់អំពី សុខុមាលភាពសង្គម បណ្តាញសង្គម និងពលកម្មកុមារ ទាក់ទងការធ្វើចំណាកស្រុកពីប្រទេសកម្ពុជា ទៅកាន់ប្រទេសថៃ ក្នុងបរិបទកូវីដ-១៩ ........ ១៧

ផលប៉ះពាល់នៃជំងឺកូវីដ-១៩លើការអប់រំរបស់ជនមានពិការភាពនៅកម្ពុជា ........ ២១

កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយស៖ វិស័យសេវាសាធារណៈនៅកម្ពុជា ........ ២៥

គម្រោងប្រាក់សោធននិវត្តន៍សម្រាប់វិស័យឯកជននៅកម្ពុជា៖ ការត្រៀមខ្លួន និងផលប៉ះពាល់នៃសុខុមាលភាពសង្គម ........ ២៥

ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងវិស័យឯកជន ក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា ........ ២៨

ការស្ម័គ្រចិត្តរបស់យុវជន អក្ខរកម្មផ្នែកឌីជីថល និងការអភិវឌ្ឍសហគមន៍៖ ករណីសិក្សាកម្មវិធីអ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំនៅកម្ពុជា និងផែនទីបង្ហាញផ្លូវសម្រាប់ក្រុមយុវវ័យ និងយុវជន ........ ៣២

សន្និដ្ឋាន ........ ៣៦

ឧបសម្ព័ន្ធទី១ ........ ៣៩

ឧបសម្ព័ន្ធទី២ ........ ៤២

## សេចក្តីថ្លែងអំណរគុណ

អង្គការមូលនិធិអាស៊ីសូមថ្លែងអំណរគុណចំពោះការរួមចំណែករបស់ ស្ថាប័នពាក់ព័ន្ធនានា និងម្ចាស់ជំនួយ ដែលបានធ្វើឱ្យកម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងរបស់កម្មវិធីពន្លកចំណេះ អាចដំណើរការទៅបានដោយរលូន។

អង្គការមូលនិធិអាស៊ី ក៏សូមអរគុណអង្គការដៃគូស្រាវជ្រាវដែលបានផ្តល់ធាតុចូល និងចូលរួមសហការក្នុងការរៀបចំកិច្ចពិភាក្សា និងអរគុណវាគ្មិនកិត្តិយស និងអ្នកសម្របសម្រួលដែលបានផ្តល់មតិយោបល់ ក្នុងអំឡុងកិច្ចពិភាក្សា ក៏ដូចជាអរគុណក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី ដែលបានផ្តល់ជំនួយថវិកា។

## អំពីកម្មវិធីពន្លកចំណេះ

កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា ជាគំនិតផ្តួចផ្តើម រយៈពេល ៤ឆ្នាំ (២០១៩-២០២៣) ដែលមានគោលបំណងពង្រឹងវិស័យស្រាវជ្រាវ និងគាំទ្រ ដល់ការវិភាគ និងពិភាក្សាអំពីគោលនយោបាយសាធារណៈនៅកម្ពុជា។ ដោយទទួលបានការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី អង្គការមូលនិធិអាស៊ីមានគោលបំណងពង្រឹងសមត្ថភាពផ្នែកស្ថាប័ន និងផ្នែកបច្ចេកទេសរបស់ស្ថាប័នស្រាវជ្រាវនៅកម្ពុជា និងបង្កើតបរិយាកាសអំណោយផលសម្រាប់ការពិភាក្សាគោលនយោបាយ។

## អំពីអង្គការមូលនិធិអាស៊ី

អង្គការមូលនិធិអាស៊ី ជាអង្គការអភិវឌ្ឍន៍អន្តរជាតិមិនស្វែងរកប្រាក់ចំណេញ ដែលប្តេជ្ញាលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ ផ្អែកតាមបទពិសោធន៍ និងជំនាញជាច្រើនទសវត្សរ៍ ការងាររបស់អង្គការមូលនិធិអាស៊ី នៅតំបន់ផ្តោតសំខាន់លើ អភិបាលកិច្ចល្អ ការបង្កើនភាពអង់អាចរបស់ស្ត្រី និងសមភាពយេនឌ័រ កំណើនសេដ្ឋកិច្ចបរិយាបន្ន សកម្មភាពបរិស្ថាន និងអាកាសធាតុ និងទំនាក់ទំនងក្នុងតំបន់ និងអន្តរជាតិ។

# អំពីអ្នករៀបចំកម្មវិធី

## ក្រុមការងារនៃអង្គការមូលនិធិអាស៊ី

ជា លីម៉េង

ជា យ៉ន

ហ៊ួន រតនា

គីម លីស៊ីវនឹង

មេឡូនី លីនប៊ឹក

ម៉ែន ពិចិត្រ

ម៉ូក ម៉ាអេឡៃន

ងិន ពិសិដ្ឋ

ភ្លួង សុធីនី

ប្រាក់ វត្តិធីរា

សារ៉េត ស្រីស្រស់

ស៊ឹម សុវចនា

ឃួម អុក

## ដៃគូស្រាវជ្រាវនៃកម្មវិធីពន្លកចំណេះ

មជ្ឈមណ្ឌលសម្រាប់ការវិភាគបញ្ហាអភិវឌ្ឍន៍
មជ្ឈមណ្ឌលខេមរសិក្សា
មជ្ឈមណ្ឌលយុទ្ធសាស្ត្រ និងគោលនយោបាយនវានុវត្តន៍
អង្គការប្រើប្រាស់ទឹកប្រកបដោយចីរភាព
សម្ព័ន្ធសិទ្ធិកុមារកម្ពុជា
មជ្ឈមណ្ឌលស្រាវជ្រាវនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង
ក្រុមប្រឹក្សាយុវជនកម្ពុជា

## ផ្តល់មូលនិធិដោយ

កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា ទទួលបានការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី និងអនុវត្តដោយអង្គការមូលនិធិអាស៊ី។

## អំណះអំណាង

កម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹង៖ ការលើកកម្ពស់វិស័យសេវាសាធារណៈសម្រាប់ក្រុមងាយរងគ្រោះនៅកម្ពុជា ទទួលបានការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី តាមរយៈកម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា របស់អង្គការមូលនិធិអាស៊ី។ ទស្សនៈដែលលើកឡើងនៅក្នុងសៀវភៅនេះ គឺជាទស្សនៈរបស់វាគ្មិនផ្ទាល់ ពោលគឺមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលី ឬអង្គការមូលនិធិអាស៊ីឡើយ។

រក្សាសិទ្ធិដោយ © អង្គការមូលនិធិអាស៊ី ២០២៣


Ms. Meloney C. Lindberg
Country Representative


Reserved

# សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាខិតខំលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដើម្បីធានាឱ្យប្រជាពលរដ្ឋ ដែលរួមមានក្រុមងាយរងគ្រោះ និងក្រុមដែលមានឱកាសតិចតួច អាចទទួលបានសេវាសាធារណៈ ប្រកបដោយសមភាព[1]។ គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ មានសមិទ្ធផលជាច្រើនត្រូវបាន សម្រេច។ ឧទាហរណ៍ មានកុមារជាង ៩៧% បានចូលរៀននៅកម្រិតបឋមសិក្សាកាលពីឆ្នាំ ២០១៧[2] ប្រជាពលរដ្ឋកម្ពុជា ៨៦,៤% មានអគ្គិសនីប្រើប្រាស់នៅក្នុងឆ្នាំ២០២០[3] និងប្រជា ពលរដ្ឋនៅជនបទ ៨០% មានទឹកស្អាត និងសេវាអនាម័យប្រើប្រាស់ក្នុងឆ្នាំ២០២២។[4]

ទោះជាយ៉ាងនេះក្តី កិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការផ្តល់សេវាសាធារណៈ ត្រូវទទួលរង ការអាក់ខាន ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ ប្រទេសកម្ពុជាត្រូវបានបិទទ្វារមួយ រយៈខ្លី មិនទទួលភ្ញៀវទេសចរអន្តរជាតិ និងមានការដាក់ឱ្យអនុវត្តនូវវិធានការរឹតត្បិតការធ្វើដំណើរ ទាំងឆ្លងប្រទេស ទាំងក្នុងប្រទេស។ ជាលទ្ធផល ពលរដ្ឋកម្ពុជា រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ និងក្រុមដែលមានឱកាសតិចតួច បានរងផលប៉ះពាល់អវិជ្ជមាន។

ឧទាហរណ៍ ក្រុមងាយរងគ្រោះមួយចំនួន ជាពិសេសជនមានពិការភាព ជួបការលំបាក ក្នុងការទទួលបានសេវា និងក្នុងការសម្របខ្លួនទៅតាមការផ្លាស់ប្តូរនៃវិធីសាស្ត្រផ្តល់សេវាសាធា រណៈ។ លទ្ធផលរកឃើញបឋម ដោយមជ្ឈមណ្ឌលស្រាវជ្រាវនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង បានបង្ហាញថា សិស្សមានពិការភាពជួបការលំបាកក្នុងការសិក្សា ដោយសារបរិយាកាសសិក្សាមាន ការផ្លាស់ប្តូរ និងខ្វះការគាំទ្រពិសេស។[5]

ជំងឺកូវីដ-១៩ ក៏ដាក់សម្ពាធមកលើធនធានធម្មជាតិផងដែរ។ ការឆ្លងរាលដាលជាសកល នេះធ្វើឱ្យប្រជាពលរដ្ឋមានតម្រូវការទឹកកាន់តែច្រើន ជាពិសេសស្ត្រី ដែលត្រូវការទឹក សម្រាប់ចម្អិនអាហារ និងសម្អាត (រួមមានទាំងការសម្អាតដៃ)។

លើសពីនេះកុមារក៏ជួបនឹងបញ្ហាអារម្មណ៍តានតឹង និងភាពអន្ទះអន្ទែងក្នុងចិត្តផងដែរ។ ការ សិក្សាមួយដែលធ្វើឡើងដោយសមាគមកុមាររីករាយបានរកឃើញថា កុមារចំនួន ៦០% ដែល ត្រូវបានសម្ភាស មានអារម្មណ៍ថាមិនសប្បាយចិត្ត ហើយកុមារចំនួន ៤០% មានអារម្មណ៍អស់ សង្ឃឹម បើធៀបនឹងអារម្មណ៍របស់ពួកគេមុនពេលដែលមានជំងឺកូវីដ-១៩ កើតឡើង។[6]

ជំងឺកូវីដ-១៩ ធ្វើឱ្យក្រុមងាយរងគ្រោះ ពិបាកនឹងបន្តមុខរបរចិញ្ចឹមជីវិត ដោយសារតែ សម ត្ថភាពពួកគេនៅមានកម្រិតក្នុងការសម្របខ្លួនទៅតាមកាលៈទេសៈថ្មីៗទាំងនេះ។ ការសិក្សាមួយ

1 https://www.khmersme.gov.kh/wp-content/uploads/2022/09/Rectangular-Strategy-Phase-IV.pdf
2 https://www.unicef.org/cambodia/education#:~:text=Cambodia%20has%20made%20terrific%20progress,in%20school%20year%202017%2F18.
3 https://data.worldbank.org/indicator/EG.ELC.ACCS.ZS?locations=KH
4 https://www.khmertimeskh.com/501123910/over-80-pct-of-cambodias-rural-population-have-access-to-clean-water-sanitation/
5 https://policypulse.org/wp-content/uploads/2023/01/NPF-booklet-20Jan23.pdf
6 https://policypulse.org/wp-content/uploads/2022/05/KMR_the-impact-of-covid-19-on-child-protection-and-wellbeing.pdf

ដែលធ្វើឡើងដោយអង្គការភូមិខ្ញុំ លើផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ មកលើជនជាតិដើមភាគតិច បានរកឃើញថា ជំងឺកូវីដ-១៩បង្កផលប៉ះពាល់លើការប្រកបរបរចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគតិចនៅក្នុងខេត្តស្ទឹងត្រែង ដោយសារពួកគេពុំមានទីផ្សារសម្រាប់លក់ផលិតផល។[7] ការបាត់បង់ប្រាក់ចំណូល ក៏ធ្វើឱ្យប្រជាពលរដ្ឋរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ រឹតតែជួបការលំបាកផងដែរ ព្រោះចំណូលប្រចាំថ្ងៃរបស់ពួកគេពុំគ្រប់គ្រាន់ សម្រាប់រ៉ាប់រងលើចំណាយម្ហូបអាហារឡើយ។[8]

ដើម្បីឆ្លើយតបទៅលើផលប៉ះពាល់ចំពោះមុខ ដែលបង្កឡើងដោយសារជំងឺកូវីដ-១៩ និងធានាយ៉ាងណាមិនឱ្យប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រជាងគេ ត្រូវបានទុកចោល រដ្ឋាភិបាលបានប្រើប្រាស់យន្តការដែលមានស្រាប់របស់ខ្លួននោះគឺ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ( ហៅកាត់ថាកម្មវិធីប័ណ្ណក្រីក្រ ) ដើម្បីផ្តល់ការឧបត្ថម្ភ គាំទ្រដល់ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រខ្លាំងអាចទទួលបានសេវាដែលចាំបាច់ ដូចជា សេវាថែទាំសុខភាព ការឧបត្ថម្ភសាច់ប្រាក់ ព្រមទាំងសេវាសង្គមដទៃទៀត។ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គ្របដណ្តប់មិនត្រឹមតែលើគ្រួសារដែលមានជីវភាពក្រោមបន្ទាត់ក្រីក្រ ប៉ុណ្ណោះទេ ថែមទាំងលើកម្មករនិយោជិតងាយរងគ្រោះជាច្រើនប្រភេទ ដូចជា កម្មករនិយោជិតក្នុងវិស័យទេសចរណ៍[9] និងពលករចំណាកស្រុកដែលបានធ្វើមាតុភូមិនិវត្តន៍មកវិញ ដោយពួកគេបានទទួលការឧបត្ថម្ភជាសាច់ប្រាក់ផង និងការឧបត្ថម្ភជារបស់របរប្រើប្រាស់ផង។[10] ត្រឹមឆ្នាំ២០២២ ប្រជាពលរដ្ឋជាង ៧០០.០០០ នាក់ នៅកម្ពុជា បានទទួលប័ណ្ណក្រីក្រ ដែលអាចឱ្យពួកគេទៅទទួលសេវានានា។[11] ជាការឆ្លើយតបចំពោះសម្ពាធសេដ្ឋកិច្ចមកលើប្រជាពលរដ្ឋក្នុងអំឡុងពេលដែលមានជំងឺកូវីដ-១៩ រដ្ឋាភិបាលក៏បានអនុវត្តនូវគោលនយោបាយជាច្រើនផងដែរ ដូចជា ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារសេដ្ឋកិច្ច និងរបបសោធនសម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន ដើម្បីពង្រឹងភាពធន់របស់កម្ពុជាចំពោះវិបត្តិនាពេលអនាគត។

ក្នុងគោលដៅពង្រឹងភាពធន់ចំពោះវិបត្តិនាពេលអនាគត និងសម្រេចបានលទ្ធផលឱ្យបានកាន់តែប្រសើររដ្ឋាភិបាលត្រូវការទិន្នន័យដែលអាចជឿទុកចិត្តបាន និងកិច្ចពិភាក្សាដែលមានលក្ខណៈបរិយាបន្ន សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តនានា។ដូច្នេះហើយ ដៃគូរបស់កម្មវិធីពន្លកចំណេះ និងស្ថាប័នស្រាវជ្រាវដទៃទៀត បានធ្វើការស្រាវជ្រាវជាច្រើនលើផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើក្រុមងាយរងគ្រោះ ក្នុងគោលបំណងស្វែងយល់ពីបញ្ហា និងការប្រឈមនានា ព្រមទាំងផ្តល់អនុសាសន៍ ដើម្បីឱ្យសេវាដែលផ្តល់ដល់ក្រុមដែលងាយរងគ្រោះ កាន់តែមានភាពល្អប្រសើរ។

7 https://policypulse.org/publications/articles/investigation-of-the-impacts-of-the-covid-19-pandemic-on-local-and-indigenous-communities-socio-economic-status/

8 https://cambojanews.com/2-8-million-cambodians-were-living-under-the-poverty-line-in-2020/

9 https://www.phnompenhpost.com/national/final-cash-support-siem-reap-tourism-workers

10 https://www.phnompenhpost.com/national-post-depth/economic-woes-back-home-migrants

11 https://nspc.gov.kh/Images/%E1%9E%9F%E1%9E%BB%E1%9E%93%E1%9F%92%E1%9E%91%E1%9E%9A%E1%9E%80%E1%9E%90%E1%9E%B6_DPM_SP_WEEK_2023_2023_02_17_07_21_40.pdf

ផ្អែកតាមគំនិតយោបល់ទទួលបានពីការសិក្សាស្រាវជ្រាវ ដែលធ្វើឡើងដោយដៃគូនៃកម្មវិធីពន្លកចំណេះកាលពីពេលថ្មីៗនេះ ក៏ដូចជាចំណេះដឹងរបស់តួអង្គសំខាន់ៗ ដែលធ្វើការងារពាក់ព័ន្ធនឹងវិស័យគោលនយោបាយ កម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងនៃកម្មវិធីពន្លកចំណេះ បានបំពេញតួនាទីជាវេទិកាសម្រាប់ឱ្យអ្នកស្រាវជ្រាវធ្វើការបង្ហាញពីរបកគំហើញរបស់ខ្លួន ពិភាក្សាផ្លាស់ប្តូរចំណេះដឹង និងកសាងបណ្តាញជាមួយអ្នកប្រើប្រាស់លទ្ធផលដែលបានរកឃើញ ពីការស្រាវជ្រាវនេះ តាមរយៈការវាយតម្លៃលើកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល និងផ្តល់ជាអនុសាសន៍ ដើម្បីឱ្យមានការផ្តល់សេវាសាធារណៈកាន់តែប្រសើរដល់ក្រុមងាយរងគ្រោះនៅកម្ពុជា។





# សុន្ទរកថាបើក



លោក Andreas Zurbrugg

ឯកអគ្គរាជទូតរងនៃស្ថានទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា

ថ្ងៃនេះ តំណាងឱ្យស្ថានទូតអូស្ត្រាលី ខ្ញុំមានកិត្តិយស សូមស្វាគមន៍ឯកឧត្តម លោកជំទាវ លោក លោកស្រី មកកាន់កម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងនៃកម្មវិធីពន្លកចំណេះ ឆ្នាំ២០២៣ រៀបចំដោយ អង្គការមូលនិធិអាស៊ី ដែលសហការជាមួយនឹងដៃគូស្រាវជ្រាវរបស់កម្មវិធីនេះ និងតួអង្គពាក់ព័ន្ធក្នុងវិស័យគោលនយោបាយ។

កម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងដែលរៀបចំនៅថ្ងៃនេះ គឺជាផ្នែកមួយនៃកម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា របស់អង្គការមូលនិធិអាស៊ី ដែលជាគំនិតផ្តួចផ្តើមរយៈពេល ៥ឆ្នាំ ពីឆ្នាំ ២០១៩-២០២៣ ក្រោមការឧបត្ថម្ភពីរដ្ឋាភិបាលអូស្ត្រាលី ក្នុងគោលបំណងពង្រឹងចំណេះដឹងស្ថាប័នស្រាវជ្រាវ ឱ្យធ្វើការស្រាវជ្រាវប្រកបដោយគុណភាព ដើម្បីគាំទ្រដល់ការវិភាគ និងពិភាក្សាគោលនយោបាយនៅកម្ពុជា។

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលវេទិកាគោលនយោបាយថ្នាក់ក្រោមជាតិនៃកម្មវិធីពន្លកចំណេះនៅឆ្នាំនេះ ផ្តោតលើការពង្រឹងវិស័យសេវាសាធារណៈ ដើម្បីធានាឱ្យមានកាផ្តល់ការគាំទ្រនិងសេវាកាន់តែប្រសើរដល់ក្រុមងាយរងគ្រោះនៅកម្ពុជា ស្របតាមការប្តេជ្ញាចិត្តរបស់ប្រទេសអូស្ត្រាលី ក្នុងការគាំទ្រ និងពង្រឹងដល់ការផ្តល់សេវាសាធារណៈសម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប។

រដ្ឋាភិបាលអូស្ត្រាលីបាន និងកំពុងផ្តល់ការគាំទ្រយ៉ាងសកម្មដល់កម្ពុជា ក្នុងការសម្រេចគោលដៅអភិវឌ្ឍរបស់ខ្លួន ដើម្បីក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ត្រឹមឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។ កិច្ចព្រមព្រៀងទ្វេភាគីរបស់យើង ក៏បានជួយឱ្យកម្ពុជាក្លាយជាប្រទេសដែលកាន់តែមានភាពធន់នឹងវិបត្តិនានា ដូចជា ការរីករាលដាលនៃជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្នជាដើម។ ក្នុងអំឡុងពេលដែលមានការរីករាលដាលនៃជំងឺនេះ ប្រទេសអូស្ត្រាលីបានចាត់វិធានការបន្ទាន់ ដើម្បីជួយដល់កម្ពុជា តាមរយៈការពង្រឹងកម្មវិធីអភិវឌ្ឍ ដែលកំពុងអនុវត្តដើម្បីឆ្លើយតបចំពោះផលប៉ះពាល់ដែលជំងឺកូវីដ-១៩ មានមកលើសន្តិសុខផ្នែកសុខភាព ស្ថេរភាពបរិយាបន្ន និងសេដ្ឋកិច្ច។

រដ្ឋាភិបាលអូស្ត្រាលី ក៏បានផ្តល់ការគាំទ្រដល់ដៃគូជាច្រើន ដែលកំពុងអនុវត្តគំនិតផ្តួចផ្តើមនានា ដើម្បីធានាឱ្យមានការផ្តល់សេវាសាធារណៈប្រកបដោយបរិយាបន្ននៅកម្ពុជា។ ឧទាហរណ៍ការអនុវត្តកម្មវិធីក្របខណ្ឌគណនេយ្យភាពសង្គម (ISAF) ដែលយើងបានផ្តល់ការគាំទ្រកន្លងមកមានគោលបំណងលើកកម្ពស់សមិទ្ធកម្មនៃអ្នកផ្តល់សេវាសាធារណៈ តាមរយៈការបង្កើនតម្លាភាព ពង្រឹងការចូលរួមរបស់ពលរដ្ឋ និងសកម្មភាពឆ្លើយតប តាមរយៈមូលនិធិបរធនបាលដែលមានការ

ចូលរួមពីអ្នកផ្តល់ជំនួយចម្រុះ (Multi-donor Trust Fund) របស់ធនាគារពិភពលោក អនុវត្ត ដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន គ.ជ.អ.ប) និងអង្គការទស្សនៈពិភពលោកអន្តរជាតិនៅក្នុងឃុំ/សង្កាត់ចំនួន ៨៦៥ សាលាបឋមសិក្សាចំនួន ៣.៨៥០ មណ្ឌលសុខភាពចំនួន ៦៩៦ និងរដ្ឋបាលស្រុកក្រុងចំនួន ២០ ដែលក្នុងនោះមានស្រុកចំនួន ៧ ឃុំចំនួន ៦២ សាលាបឋមសិក្សាចំនួន ៣២៤ និងមណ្ឌលសុខភាពចំនួន ៥៥ ស្ថិតនៅក្នុងខេត្តសៀមរាប។ ប្រទេសអូស្ត្រាលីបានជួយកម្ពុជា ក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនពលរដ្ឋក្រីក្រ តាមរយៈការអនុវត្តគម្រោងលើកកម្ពស់សមធម៌ និងគុណភាពសេវាសុខាភិបាល (HEQIP) ដូចជា ការបង្កើនគុណភាពសេវាសុខភាពនៅក្នុងមណ្ឌលសុខភាព និងមន្ទីរពេទ្យសាធារណៈ ប្រមាណ ១.៣០០ កន្លែងនៅទូទាំងប្រទេស។ ក្នុងខេត្តសៀមរាប គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល (H-EQIP) ត្រូវបានអនុវត្តក្នុងមន្ទីរពេទ្យចំនួន ៥ មណ្ឌលសុខភាពចំនួន ៩៣ និងប៉ុស្តិ៍សុខភាពចំនួន ១។ តាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីផ្តល់សេវាប្រកបដោយសមធម៌ និងចីរភាព (ACCESS) អូស្ត្រាលីក៏បង្កើនគុណភាព និងនិរន្តរភាពនៃសេវាសម្រាប់ជនមានពិការភាព និងជនរងគ្រោះដោយអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រផងដែរ តាមរយៈការសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ដើម្បីគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP) របស់កម្ពុជាក្នុងខេត្តចំនួន ១៥ ក្នុងនោះមានការផ្តោតការយកចិត្តទុកដាក់ជាពិសេសលើខេត្តគោលដៅចំនួន ៣ ដែលរួមមានខេត្តសៀមរាបផងដែរ។ ភាពជាដៃគូរបស់យើងជាមួយវិស័យឯកជន តាមរយៈកម្មវិធីវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ (3i) បានផ្តល់លទ្ធភាពឱ្យប្រទេសអូស្ត្រាលីអាចជួយឱ្យគ្រួសារកម្ពុជា ទទួលបានការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ និងអគ្គិសនីប្រើប្រាស់ ហើយប្រទេសអូស្ត្រាលីក៏គាំទ្រឱ្យពលរដ្ឋកម្ពុជាដែលក្រីក្រ និងមានឱកាសតិចតួច អាចទទួលបានការឧបត្ថម្ភពីរបបគាំពារសង្គម និងសេវាសាធារណៈ តាមរយៈការគាំទ្ររបស់យើងដល់ប្រព័ន្ធចុះបញ្ជីគ្រួសារក្រីក្ររបស់កម្ពុជា (កម្មវិធីប័ណ្ណក្រីក្រ)។

ជាជំហានបន្ទាប់ដើម្បីបង្កើនភាពធន់នឹងវិបត្តិដែលអាចកើតមានឡើងនាពេលអនាគតនិងសម្រេចបានលទ្ធផលឱ្យបានកាន់តែប្រសើរ យើងប្តេជ្ញាជួយឱ្យរដ្ឋាភិបាលកម្ពុជាអាចទទួលបាន និងប្រើប្រាស់ទិន្នន័យដែលអាចជឿទុកចិត្តបានសម្រាប់ធ្វើគោលនយោបាយ ក៏ដូចជា សម្របសម្រួលកិច្ចពិគ្រោះយោបល់គោលនយោបាយ ដែលមានលក្ខណៈបរិយាបន្ន ដើម្បីផ្តល់ជាព័ត៌មានដល់ការរៀបចំគោលនយោបាយដែលឆ្លើយតបនឹងតម្រូវការ ព្រមទាំងជានាប្រយោជន៍សម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប។ ការងារដែលយើងបានអនុវត្ត ដើម្បីពង្រឹងវិស័យស្រាវជ្រាវ និងសមត្ថភាពរបស់តួអង្គសង្គមស៊ីវិលនៅកម្ពុជា តាមរយៈកម្មវិធីពន្លកចំណេះនៃអង្គការមូលនិធិអាស៊ី គឺជាការរួមចំណែកដ៏ធំមួយ ដើម្បីសម្រេចគោលដៅនេះ។

រហូតមកដល់បច្ចុប្បន្ននេះ ដៃគូទទួលបានថវិកាគាំទ្រពីកម្មវិធីពន្លកចំណេះ ដូចជា មជ្ឈមណ្ឌលសម្រាប់ការវិភាគបញ្ហាអភិវឌ្ឍនៅកម្ពុជា (ADIC) មជ្ឈមណ្ឌលខេមរសិក្សា (CKS) មជ្ឈមណ្ឌលគោលនយោបាយយុទ្ធសាស្ត្រ និងនវានុវត្តន៍ (CSIP) មជ្ឈមណ្ឌលប្រើប្រាស់ទឹកប្រកប

ដោយចីរភាព (CSW) អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា (CRC) និងមជ្ឈមណ្ឌលស្រាវជ្រាវនៃសកលវិទ្យាល័យជាតិគ្រប់គ្រង បានធ្វើការស្រាវជ្រាវ ដើម្បីស្វែងយល់ពីផលប៉ះពាល់ដែលជំងឺកូវីដ-១៩ មានលើសេវាសាធារណៈសម្រាប់ក្រុមងាយរងគ្រោះ ដូចជា ពលករទេសន្តរប្រវេសក៍ និងជនមានពិការភាពជាដើម។ ជាជំហានបន្ទាប់ យើងសង្ឃឹម និងរំពឹងថា ការស្រាវជ្រាវ និងកិច្ចពិគ្រោះយោបល់ជាបន្តបន្ទាប់ស្តីពី សេវាសាធារណៈសម្រាប់ក្រុមងាយរងគ្រោះ ព្រមទាំងបញ្ហាគោលនយោបាយពាក់ព័ន្ធដទៃទៀត នឹងត្រូវធ្វើឡើង ក៏ដូចជា លើកយកមកធ្វើការពិភាក្សាតាមរយៈកម្មវិធីពន្លកចំណេះ។

តាមរយៈការឧបត្ថម្ភរបស់ប្រទេសអូស្ត្រាលីដល់កម្មវិធីពន្លកចំណេះនៃអង្គការមូលនិធិអាស៊ី យើងសង្ឃឹមថា យើងនឹងអាចចូលរួមសហការកាន់តែស៊ីជម្រៅជាមួយនឹងក្រុមបញ្ញវ័ន្តជួរមុខ ស្ថាប័នស្រាវជ្រាវ និងតួអង្គពាក់ព័ន្ធក្នុងវិស័យគោលនយោបាយនៅកម្ពុជា ដើម្បីសហការផ្តល់នូវទិន្នន័យ និងភស្តុតាងនានាដល់អ្នកធ្វើគោលនយោបាយសំខាន់ៗ ក៏ដូចជាធានាឱ្យមានកិច្ចពិគ្រោះយោបល់ និងកិច្ចពិភាក្សាឱ្យបានជាទៀងទាត់ប្រកបដោយបរិយាបន្នក៏ដូចជាពង្រឹងបណ្តាញរវាងបញ្ញវ័ន្ត ស្ថាប័នស្រាវជ្រាវ និងតួអង្គគោលនយោបាយនៅក្នុងប្រទេស និងនៅក្នុងតំបន់។ កម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងនៃកម្មវិធីពន្លកចំណេះ គឺជាកិច្ចខិតខំប្រឹងប្រែងមួយ ក្នុងចំណោមកិច្ចខិតខំប្រឹងប្រែងសំខាន់ៗ ដែលបានទទួលការឧបត្ថម្ភគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី ជាពិសេសនៅថ្នាក់ក្រោមជាតិ ដែលរួមចំណែកដល់ការបន្តអភិវឌ្ឍកម្ពុជា។

កម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹង ផ្តោតលើការលើកកម្ពស់វិស័យសេវាសាធារណៈសម្រាប់ក្រុមងាយរងគ្រោះនៅកម្ពុជា ដែលរៀបចំនៅថ្ងៃនេះ គឺជាវេទិកាមួយសម្រាប់ឱ្យតួអង្គដែលធ្វើការងារក្នុងវិស័យស្រាវជ្រាវ ដូចជា អ្នកស្រាវជ្រាវ អ្នកធ្វើគោលនយោបាយ និងអ្នកសិក្សាអាចចែករំលែក និងពិភាក្សាពីលទ្ធផលរកឃើញ ផ្លាស់ប្តូរគំនិត ចងក្រងបណ្តាញជាមួយគ្នា និងផ្តល់អនុសាសន៍សម្រាប់ការធ្វើគោលនយោបាយ និងរៀបចំកម្មវិធីនៅក្នុងវិស័យនេះនាពេលអនាគត។ ខ្ញុំសង្ឃឹមថាឯកឧត្តមលោកជំទាវលោកលោកស្រីនឹងទទួលបានឱកាសដ៏មានតម្លៃក្នុងកិច្ចពិគ្រោះយោបល់នេះ ដើម្បីធ្វើការផ្លាស់ប្តូរចំណេះដឹង ស្គាល់ពីគ្នាទៅវិញទៅមក និងសហការជាមួយគ្នាបន្ថែមទៀត។ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះអ្នកជំនាញជាច្រើននាក់មកពីរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ សាកលវិទ្យាល័យ អង្គការក្រៅ រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដែលចំណាយពេលវេលាចែករំលែកចំណេះដឹង និងលទ្ធផលរកឃើញ ដែលបានពីការស្រាវជ្រាវរបស់ខ្លួនក្នុងកម្មវិធីនៅថ្ងៃនេះ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការមូលនិធិអាស៊ី និងដៃគូនៃកម្មវិធីពន្លកចំណេះ ដែលបានរៀបចំកម្មវិធីដ៏មានសារៈសំខាន់នេះឡើង និងអរគុណចំពោះអ្នកចូលរួមទាំងអស់ដែលចំណាយពេលវេលា និងចូលរួមផ្តល់មតិយោបល់ក្នុងកម្មវិធីនេះ។ ខ្ញុំសូមជូនពរឱ្យកម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងនាថ្ងៃនេះ ទទួលបានលទ្ធផលជាផ្លែផ្កា ហើយខ្ញុំជឿជាក់ថា បន្ទាប់ពីកម្មវិធីនេះ លោកអ្នកនឹងនាំទៅជាមួយនឹងគំនិត យោបល់ ព្រមទាំងមេរៀន បទពិសោធន៍ថ្មីៗជាច្រើនជាមិនខាន។

# សុន្ទរកថាគន្លឹះ



**លោក ចឹង គឹមជុន**
នាយករងរដ្ឋបាលខេត្តសៀមរាប

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយឥតឧបមា ដែលមានឱកាសថ្លែងសន្ទរកថាគន្លឹះក្នុងកម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹង ក្រោមប្រធានបទ "ការលើកកម្ពស់វិស័យសេវាសាធារណៈសម្រាប់ក្រុមងាយរងគ្រោះនៅកម្ពុជា" ជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់គ្នា។ ឆ្លៀតឱកាសនេះ ខ្ញុំសូមស្វាគមន៍វត្តមានលោក Andreas Zurbrugg តំណាងស្ថានទូតអូស្ត្រាលីនៅកម្ពុជា ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានមន្ទីរ និងអង្គការពាក់ព័ន្ធដែលបានឆ្លៀតពេលដ៏មមាញឹកចូលរួមក្នុងកម្មវិធីពិភាក្សាដ៏មានសារៈសំខាន់នេះ។ ទន្ទឹមគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះអង្គការមូលនិធិអាស៊ី ដែលបានផ្តួចផ្តើម និងចូលរួមសហការរៀបចំកិច្ចពិគ្រោះយោបល់នេះ ក្នុងគោលបំណង ១) ផ្សព្វផ្សាយពីលទ្ធផលនៃការស្រាវជ្រាវ និងទិន្នន័យឆ្លើយតបចំពោះតម្រូវការគោលនយោបាយក្នុងគោលបំណងផ្តល់ជាព័ត៌មាន ដើម្បីរៀបចំសេវាសាធារណៈនៅកម្ពុជាឱ្យឆ្លើយតបកាន់តែប្រសើរចំពោះតម្រូវការរបស់ក្រុមងាយរងគ្រោះ ២) ជំរុញឱ្យមានការពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងរវាងអ្នកពាក់ព័ន្ធនានា នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត និង ៣) កសាងបរិយាកាសដែលតួអង្គពាក់ព័ន្ធក្នុងវិស័យស្រាវជ្រាវអាចជួបគ្នាពិភាក្សា និងពង្រីកបណ្តាញរបស់ពួកគេ ដើម្បីកសាងសហគមន៍ក្នុងវិស័យស្រាវជ្រាវឱ្យកាន់តែរឹងមាំនៅថ្នាក់ខេត្ត។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!

ដូចដែលអ្នកទាំងអស់គ្នាបានជ្រាបហើយ កន្លងមក ក៏ដូចជា នាពេលបច្ចុប្បន្ននេះ ក្រោមការដឹកនាំនៃប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ បើទោះជាការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានបង្កជាឧបសគ្គដល់សហគមន៍ទូទាំងប្រទេសក៏ដោយ រាជរដ្ឋាភិបាលកម្ពុជារបស់យើងបាន និងកំពុងតស៊ូយ៉ាងស្វិតស្វាញ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃវីរុសដ៏កំណាចនេះ និងបានទទួលជោគជ័យ ធ្វើឱ្យស្ថានភាពរបស់ប្រជាពលរដ្ឋវិលមករកភាពប្រក្រតីវិញ។ លើសពីនេះ រាជរដ្ឋាភិបាលកម្ពុជាក៏កំពុងផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីជម្នះបញ្ហាប្រឈមនានា និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ ការពារសុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ដូចជា តាមរយៈការផ្តល់នូវ វ៉ាក់សាំងដូសដំបូង និងដូសជំរុញ ដើម្បីលើកទឹកចិត្តឱ្យប្រជាពលរដ្ឋមកទទួលវ៉ាក់សាំង ផ្តល់ការឧបត្ថម្ភគោលនយោបាយដល់ជនមានពិ

ការភាពនៅតាមសហគមន៍ អនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ប្រជាពលរដ្ឋក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ការឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារងាយរងគ្រោះដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារទឹកជំនន់ និងសម្ពាធអតិផរណា។ល។ រាល់ការឧបត្ថម្ភដល់ក្រុមគោលដៅខាងលើនេះ គឺធ្វើឡើងតាមរយៈការគ្រប់គ្រង និងការសម្របសម្រួលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានមូលនិធិជាតិគាំពារសង្គមជាសេនាធិការអនុវត្តកម្មវិធីទាំងនេះ ហើយដែលបានទទួលការបណ្តុះបណ្តាលតាមរយៈកិច្ចប្រជុំ ឬសិក្ខាសាលានានា។ សាលារៀនបំពេញតួនាទីសំខាន់ក្នុងការផ្សព្វផ្សាយចំណេះដឹងបច្ចេកទេស និងបទពិសោធន៍នានាដោយមន្ត្រីនៅថ្នាក់ខេត្ត និងថ្នាក់ក្រោមជាតិជាប្រចាំ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!

កិច្ចពិភាក្សានៅថ្ងៃនេះ នឹងឆ្លុះបញ្ចាំងលើវឌ្ឍនភាពទាំងវិជ្ជមាន និងអវិជ្ជមាន មេរៀនបទពិសោធន៍ដែលបានទទួលកន្លងមក ក៏ដូចជា វឌ្ឍនភាពដែលសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈជូនក្រុមងាយរងគ្រោះនៅកម្ពុជាជារួម និងនិយាយដោយឡែកក្នុងការបំពេញភារកិច្ចរបស់ខ្លួន ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ កម្មវិធីផ្តល់ជំនួយសង្គមជាសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ កម្មវិធីកំណត់អត្តសញ្ញាណជនមានពិការភាព និងការតាមដានការចាក់វ៉ាក់សាំងរបស់ប្រជាពលរដ្ឋនៅក្នុងឆ្នាំកន្លងមកនេះ។ កិច្ចពិភាក្សានេះនឹងផ្តល់ឱកាសឱ្យអ្នកទាំងអស់គ្នា ធ្វើការពិនិត្យ និងឆ្លុះបញ្ចាំងលើការ អនុវត្តគោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រជាតិ ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងការពារសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ ដូច្នេះ ខ្ញុំសូមលើកទឹកចិត្តឱ្យឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលជាសមាជិកនៃវេទិកានៅថ្ងៃនេះ យកចិត្តទុកដាក់តាមដាន និងផ្តល់មតិយោបល់ឱ្យបានល្អៗ ដើម្បីឱ្យការបំពេញភារកិច្ចរបស់ខ្លួនកាន់តែទទួលបានលទ្ធផលល្អប្រសើរ។

ជាថ្មីម្តងទៀត ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ និងកោតសរសើរដល់សមាជិកក្រុមការងារ ដែលខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនក្នុងការសម្របសម្រួល តាមដាន ពិនិត្យ ផ្សព្វផ្សាយ និងសហការដោះស្រាយរាល់បញ្ហាប្រឈមទាំងអស់ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រីមានផ្ទៃពោះ កុមារ និងជនមានពិការភាពនៅតាមគ្រួសារដែលមានជីវភាពក្រីក្រ។ ខ្ញុំសូមលើកទឹកចិត្តឱ្យអ្នកទាំងអស់គ្នាបន្តសហការគ្នាឱ្យបានកាន់តែប្រសើរ និងធ្វើការងារបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ត្បិតការងារសង្គមកិច្ច គឺជាវិជ្ជាជីវៈមួយ ដែលផ្អែកលើការអនុវត្ត និងការពង្រឹងវិន័យ ដែលជំរុញឱ្យមានការផ្លាស់ប្តូរ និងការអភិវឌ្ឍក្នុងសង្គមភាពចម្រុះគ្នានៅក្នុងសង្គម និងការផ្តល់ភាពអង់អាចដល់ប្រជាពលរដ្ឋ។ ការជួយដល់ប្រជាពលរដ្ឋដោយមានការគោរពតាមគោលការណ៍យុត្តិធម៌ សិទ្ធិ និងការទទួលខុសត្រូវរួមគ្នា គឺជាគន្លឹះដ៏សំខាន់នៃការងារសង្គមកិច្ច។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី អង្គការមូលនិធិអាស៊ី និងដៃគូស្រាវជ្រាវទាំងអស់របស់កម្មវិធីពន្លកចំណេះ ដែលបានរៀបចំព្រឹត្តិការណ៍ដ៏មានអត្ថន័យនេះ និងបានជ្រើសរើសខេត្តសៀមរាបដែលជាខេត្តទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រដ៏ល្បីល្បាញរបស់កម្ពុជា និងរបស់ពិភពលោកដើម្បីរៀបចំកិច្ចពិភាក្សា ដែលមានសារៈសំខាន់ជាមួយអ្នកស្រាវជ្រាវ អ្នកធ្វើគោលនយោបាយ អ្នកជំនាញ អ្នកទទួលសេវា អង្គការសង្គមស៊ីវិល ព្រមទាំងតួអង្គពាក់ព័ន្ធនានា ដែលកំពុងចូលរួមផ្តល់សេវាសង្គម ដែលនឹងផ្តល់នូវមតិយោបល់ជួយឱ្យយើងអាចសម្រេចគោលដៅដែលយើងចង់បាន និងលើកកម្ពស់ការផ្តល់សេវាសាធារណៈដល់ក្រុមងាយរងគ្រោះ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានចូលរួមនៅក្នុងកម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹង ក្រោមប្រធានបទ "ការលើកកម្ពស់វិស័យសេវាសាធារណៈសម្រាប់ក្រុមងាយរងគ្រោះនៅកម្ពុជា" នៅថ្ងៃនេះ ហើយខ្ញុំសូមជូនពរឱ្យអ្នកទាំងអស់គ្នា មានសុខភាពមាំមួន វិបុលភាព និងជោគជ័យគ្រប់ភារកិច្ចទាំងអស់។



# ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដើម្បីជួយគាំទ្រដល់ក្រុមងាយរងគ្រោះនៅថ្នាក់ក្រោមជាតិ




រាជរដ្ឋាភិបាលកម្ពុជាខិតខំលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដើម្បីធានាយ៉ាងណាឱ្យប្រជាពលរដ្ឋ រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ និងក្រុមដែលមានឱកាសតិចតួច អាចទទួលបានសេវាសាធារណៈប្រកបដោយសមភាព។[12] ទោះជាយ៉ាងនេះក្តី កិច្ចខិតខំប្រឹងប្រែងនេះត្រូវទទួលរងការអាក់ខានដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ ប្រជាជនកម្ពុជា រួមទាំងក្រុមងាយរងគ្រោះ និងក្រុមដែលមានឱកាសតិចតួចបានរងផលប៉ះពាល់អវិជ្ជមាន ដោយសារការរីករាលដាលនៃជំងឺនេះ ការអនុវត្តវិធានការទប់ស្កាត់ការឆ្លងរាលដាល និងការផ្លាស់ប្តូរភាពងាយស្រួលក្នុងការទទួលបានសេវា។

ការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន រាប់បញ្ចូលទាំងក្រុមដែលមានឱកាសតិចតួច និងក្រុមងាយរងគ្រោះដែលត្រូវទទួលរងការបាត់បង់ប្រាក់ចំណូល ជួបការលំបាកផ្នែកសេដ្ឋកិច្ច និងបញ្ហាសុខភាព។ រដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) ដូចជា រដ្ឋបាលខេត្តសៀមរាបជាដើម បានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការជួយដល់រដ្ឋាភិបាលនៅថ្នាក់ជាតិ ក្នុងការអនុវត្តកម្មវិធីសំខាន់ៗ ដូចជា កម្មវិធីឧបត្ថម្ភសាច់ប្រាក់ និងយុទ្ធនាការចាក់វ៉ាក់សាំងជូនក្រុមដែលប្រឈមនឹងហានិភ័យ និងក្រុមដែលគេពិបាកចុះទៅដល់។ រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏បានផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឆ្លើយតបនឹងតម្រូវការជាមូលដ្ឋាន ដូចជា ស្បៀងអាហារ និងបានជួយសម្រួលការទទួលបានសេវាសុខភាព

[12] https://www.khmersme.gov.kh/wp-content/uploads/2022/09/Rectangular-Strategy-Phase-IV.pdf

ចាំបាច់សំខាន់ៗ ដើម្បីធានាយ៉ាងណាឱ្យពលរដ្ឋគ្រប់រូប រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ និងក្រុមដែលមានឱកាសតិចតួច អាចទទួលបាន និងប្រើប្រាស់សេវាចាំបាច់សំខាន់ៗទាំងនេះ។

កិច្ចពិភាក្សារួមក្រោមប្រធានបទ "ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដើម្បីគាំទ្រដល់ក្រុមងាយរងគ្រោះនៅថ្នាក់ក្រោមជាតិ" នេះ គឺជាផ្នែកមួយនៃកម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹង ដើម្បីពិភាក្សា និងស្វែងយល់ពីតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដើម្បីគាំទ្រដល់ក្រុមងាយរងគ្រោះ ក្នុងការទប់ទល់នឹងវិបត្តិ និងភាពមិនប្រាកដប្រជាដែលអាចកើតមាននាពេលអនាគត។

## សង្ខេបលទ្ធផលនៃកិច្ចពិភាក្សា

ការផ្តល់សេវាសាធារណៈ គឺជាយន្តការសម្រាប់ផ្តល់សេវាសាធារណៈដល់សាធារណៈជនទូទៅ ដែលអនុវត្តដោយអាជ្ញាធរ ឬរដ្ឋបាលនៅថ្នាក់មូលដ្ឋាន និងថ្នាក់ក្រុង។ ក្រុមងាយរងគ្រោះ គឺជាក្រុមជួបការលំបាក ដែលធ្វើឱ្យពួកគេមិនអាចបំពេញតម្រូវការចាំបាច់របស់ខ្លួនបាន។ ពួកគេរួមមាន ស្ត្រីជាមេគ្រួសារ កុមារ ជនមានពិការភាព មនុស្សចាស់ជរា និងអ្នកដែលជួបការលំបាកនៅក្នុងសង្គម។ ដូច្នេះ ជាការសំខាន់ និងចាំបាច់ ដែលក្រុមងាយរងគ្រោះ ត្រូវអាចទទួលបានសេវាសាធារណៈ។

ក្នុងអំឡុងពេលដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩ រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជារដ្ឋបាលខេត្តសៀមរាបជាដើម បានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តកម្មវិធីសំខាន់ៗនៅថ្នាក់ក្រោមជាតិ ដូចជា កិច្ចខិតខំប្រឹងប្រែងចាក់វ៉ាក់សាំងជូនក្រុមដែលប្រឈមនឹងហានិភ័យ និងក្រុមដែលពិបាកទៅដល់ ក៏ដូចជាកម្មវិធីឧបត្ថម្ភសាច់ប្រាក់។ រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏បានជួយសម្រួលដល់ការបំពេញតម្រូវការជាមូលដ្ឋាន ដូចជា អាហារ និងសេវាសុខភាពសំខាន់ៗផងដែរ។ លើសពីនេះ រដ្ឋបាលខេត្តសៀមរាបបានប្រើប្រាស់ថវិកាខេត្ត ដើម្បីផ្តល់ការឧបត្ថម្ភដល់មន្ទីរពេទ្យនៅថ្នាក់ក្រោមជាតិ ត្បិតថវិកាមិនមានគ្រប់គ្រាន់ឡើយ ក្នុងអំឡុងពេលដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩។ រដ្ឋបាលខេត្តសៀមរាប ក៏បានផលិតប័ណ្ណគ្រួសារក្រីក្រចំនួន ២០.០០០ ប័ណ្ណផងដែរ នៅក្នុងរយៈពេលនោះ។

ដើម្បីធានា ឱ្យក្រុមងាយរងគ្រោះ ដូចជា គ្រួសារក្រីក្រ ជនមានពិការភាព មនុស្សចាស់ជរា អាចទទួលបានសេវាចាំបាច់ប្រកបដោយសមភាព រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះមានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដែរនោះ បានចែកប័ណ្ណគ្រួសារក្រីក្រដល់គ្រួសារដែលមានជីវភាពក្រីក្រ។ មនុស្សចាស់ និងកុមារអាយុក្រោម ២ឆ្នាំ បានទទួលការឧបត្ថម្ភបន្ថែម។ មន្ត្រីនៅថ្នាក់ក្រោមជាតិ (ដែលហៅថា ក្រុមរហ័ស) បានសម្ភាសក្រុមងាយរងគ្រោះ ដើម្បីស្វែងយល់ថាតើពួកគេប្រើប្រាស់ការឧបត្ថម្ភ ដែលផ្តល់ដោយមន្ទីរយ៉ាងដូចម្តេចខ្លះ។

អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍ ក៏បំពេញតួនាទីសំខាន់ក្នុងការផ្តល់សេវាទាំងនេះផងដែរ។ ជាទូទៅ អង្គការសង្គមស៊ីវិលបំពេញតួនាទីជាអ្នកគាំទ្រ និងជាអ្នកពិនិត្យ ខណៈពេលដែល

រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញតួនាទីជាអ្នកឆ្លើយតប។ អង្គការសង្គមស៊ីវិល អាចកំណត់ពីតម្រូវការបន្ថែម និងចន្លោះប្រហោង ក៏ដូចជា ផ្ដល់ជំនាញ និងចំណេះដឹងនានាដល់ប្រជាពលរដ្ឋ។ លើសពីនេះ អង្គការសង្គមស៊ីវិល ក៏ផ្ដល់នូវការកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជួយឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិអាចផ្ដល់សេវាកាន់តែមានប្រសិទ្ធភាព និងដាក់ចេញនូវស្តង់ដារគុណភាព។ លើសពីនេះ អង្គការសង្គមស៊ីវិល ក៏ខិតខំបង្កើនគណនេយ្យភាពសង្គមផងដែរ ដែលនេះជាក្របខណ្ឌមួយដ៏សំខាន់ ដើម្បីជួយពង្រឹងការផ្ដល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ។ ការផ្ដល់សេវាសាធារណៈភាគច្រើន ជាពិសេសដល់ក្រុមងាយរងគ្រោះ ផ្ដោតលើសុខភាព អាហារូបត្ថម្ភ ទឹកស្អាត ការអប់រំ កិច្ចការការពារកុមារ សកម្មភាពសេដ្ឋកិច្ច និងកម្មវិធីផ្ដោតលើការប្រែប្រួលអាកាសធាតុ តាមរយៈការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម (ISAF)។ គួរឱ្យសោកស្ដាយ ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ សកម្មភាពនានា ដូចជា ការបណ្ដុះបណ្ដាលជាដើម ត្រូវបានពន្យាពេល ឬលុបចោល។ សកម្មភាពអប់រំទាំងអស់ ត្រូវបានផ្អាកដោយសារតែសាលារៀនត្រូវបានបិទទ្វារ។

អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល បំពេញតួនាទីយ៉ាងសំខាន់ ដើម្បីជួយគាំទ្រដល់តម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងអំឡុងពេលនេះ។ អង្គការមួយចំនួនបានផ្ដល់ការឧបត្ថម្ភជាសម្ភារៈដល់មណ្ឌលសុខភាព ដូចជា អាល់កុល ទឹកលាងសម្អាតដៃ ស្រោមដៃ ម៉ាស់ និងរបស់របរប្រើប្រាស់ផ្សេងទៀត ដើម្បីឱ្យបុគ្គលសុខាភិបាលបំពេញការងារឱ្យបានសមស្រប។ អង្គការផ្សេងទៀត ធ្វើសកម្មភាពឆ្លើយតបចំពោះកំណើននៃករណីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ (GBV)។ លើសពីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំកន្លែងនៅការិយាល័យរដ្ឋបាលរបស់ខ្លួន ដើម្បីឱ្យកុមារបានមកធ្វើការសិក្សា។ ចុងក្រោយ អង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានសហការជាមួយគ្នា ដើម្បីផ្ដល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ។

លើសពីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិបាន និងកំពុងតាមដានព័ត៌មាននានា ដើម្បីធានាយ៉ាងណាឱ្យគោលនយោបាយ ក៏ដូចជា យន្តការផ្ដល់សេវាសាធារណៈ បានគ្របដណ្ដប់ដល់ក្រុមងាយរងគ្រោះ។ មេភូមិ មេឃុំ ចៅសង្កាត់ អភិបាលក្រុង និងអភិបាលខេត្តសុទ្ធតែទំនាក់ទំនងគ្នាតាមថ្នាលបច្ចេកវិទ្យាអនឡាញ ក្នុងអំឡុងពេលដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩ ដើម្បីអាចតាមទាន់សភាពការណ៍ និងទទួលបានព័ត៌មានបច្ចុប្បន្នភាព។ ដូចគ្នានេះដែរ រដ្ឋបាលថ្នាក់ក្រោមជាតិក៏បានប្រមូលព័ត៌មានពីតាមឃុំ ស្រុក តាមរយៈរបាយការណ៍នានា និងតាមការទំនាក់ទំនងទៅប្រជាពលរដ្ឋដោយផ្ទាល់តាមទូរស័ព្ទ។ ឧទាហរណ៍ រដ្ឋបាលខេត្តសៀមរាបបានផ្ដល់អាទិភាពជូនប្រជាពលរដ្ឋក្រីក្រចំនួន៩០.០០០នាក់ ដើម្បីជួយឱ្យប្រជាពលរដ្ឋទាំងនេះបានទទួលសេវាក្នុងអំឡុងពេលដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋបាលខេត្តបានសហការជាមួយនឹងអង្គការអភិវឌ្ឍន៍អន្តរជាតិអាល្លឺម៉ង់ (GIZ) តាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីផ្ដល់សេវាប្រកបដោយសមធម៌ និងចីរភាព (ACCESS) និងធនាគារពិភពលោក ដើម្បីបន្តជួបប្រជុំគ្នា និងរៀបចំជាផែនការសកម្មភាព ដើម្បីផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្រីក្រទាំង ៩០.០០០ នាក់។

មានការលើកឡើងនូវសំណូមពរមួយចំនួន ដើម្បីពង្រឹងការផ្តល់សេវាសាធារណៈជូនក្រុមងាយរងគ្រោះនៅថ្នាក់ក្រោមជាតិ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍ គួររៀបចំឡើងដោយមានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីផ្តល់ឱកាសឱ្យពួកគេ អាចចូលរួមក្នុងដំណើរការទាំងមូល ក៏ដូចជាធានានូវបរិយាបន្ន និងភាពឆ្លើយតបចំពោះយេនឌ័រ។ គួរមានយន្តការផ្តល់មតិត្រឡប់ ដែលមានលក្ខណៈបរិយាបន្ន និងមានការរក្សាការសម្ងាត់ ដើម្បីធានាឱ្យមានការឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។ លើសពីនេះ គួរមានទិន្នន័យ ដើម្បីជួយដល់ការរៀបចំគោលនយោបាយ និងការអនុវត្តគោលនយោបាយផងដែរ។ ចំណុចសំខាន់ផងដែរនោះ គឺត្រូវធានាឱ្យមានការបែងចែកធនធានឱ្យបានកាន់តែច្រើន ដើម្បីឆ្លើយតបចំពោះបញ្ហាសង្គម ដែលក្រុមងាយរងគ្រោះកំពុងជួបប្រទះ។

## វាគ្មិន និងអ្នកសម្របសម្រួល

**អ្នកសម្របសម្រួល**



**លោកស្រី អេង ចាន់ឌី**

នាយិកាប្រតិបត្តិ
នៃអង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា

**វាគ្មិនកិត្តិយស**



**លោក ចឹង គឹមជុន**

នាយករងរដ្ឋបាលសាលា
ខេត្តសៀមរាប



**លោក បឹង ពេជ្រ**

មន្ត្រីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តសៀមរាប



**លោកស្រី ចាន់ សុភា**

អ្នកគ្រប់គ្រងជាន់ខ្ពស់សម្រាប់ការចូលរួមសហគមន៍ នៃអង្គការទស្សនៈពិភពលោកអន្តរជាតិ



**លោកស្រី លី ផារ៉ុម**

អ្នកសម្របសម្រួលប្រចាំខេត្តសៀមរាប
នៃអង្គការបន្ទាយស្រី



# កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយស៖ ក្រុមងាយរងគ្រោះនៅកម្ពុជា

## ភាពធន់ និងការស្តារឡើងវិញ របស់បុគ្គលិកបម្រើការតាមសណ្ឋាគារនៅកម្ពុជា




ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ខេត្តសៀមរាបគឺ ជាខេត្តដែលរងផលប៉ះផ្នែកសេដ្ឋកិច្ចធ្ងន់ធ្ងរជាងគេមួយនៅកម្ពុជា ដែលក្នុងនោះសហគ្រាសផ្តល់សេវាបដិសណ្ឋារកិច្ចជិត ៩០% នៅក្នុងខេត្តនេះ ត្រូវផ្អាកសកម្មភាពមិនមានការកំណត់ពេលវេលា ឬបិទប្រតិបត្តិការអាជីវកម្មរបស់ខ្លួនទាំងស្រុងតែម្តង។ បើតាមរបាយការណ៍សង្ខេបខែមិថុនា ឆ្នាំ២០២២ នៃមន្ទីរទេសចរណ៍ខេត្តសៀមរាប ក្នុងចំណោមសហគ្រាសដែលបានចុះបញ្ជីជាផ្លូវការជាមួយនឹងក្រសួងមានសណ្ឋាគារចំនួន ២៣០ ដែលមានបុគ្គលិកចំនួន ១២.៥៩២ នាក់ និងផ្ទះសំណាក់ចំនួន ២៦១ កន្លែង ដែលមានបុគ្គលិកចំនួន ២.០៥៧ នាក់។ របាយការណ៍នេះបង្ហាញថា ដោយសារជំងឺកូវីដ-១៩ សណ្ឋាគារយ៉ាងហោចណាស់ចំនួន ១៨ និងផ្ទះសំណាក់ចំនួន ១២៩ បានបិទទ្វារជាអចិន្ត្រៃយ៍ ខណៈពេលដែលសណ្ឋាគារចំនួន ១៦៨ និងផ្ទះសំណាក់ចំនួន ៥៦ បានផ្អាកប្រតិបត្តិការ ហើយសណ្ឋាគារចំនួន ៤៤ និងផ្ទះសំណាក់ ៧៦ បើកដំណើរការតែផ្នែកខ្លះប៉ុណ្ណោះ។ ការបិទទ្វារ និងការព្យួរប្រតិបត្តិការអាជីវកម្ម នៃសហគ្រាសដែលផ្តល់សេវាបដិសណ្ឋារកិច្ច បានបង្កផលប៉ះពាល់ដល់បុគ្គលិកប្រមាណ ៨.០០០ នាក់។ ព្រឹត្តិការណ៍មិនធ្លាប់កើតមានឡើងនេះ នាំមកនូវសំណួរចោទសួរពីផលប៉ះពាល់រយៈពេលវែង ដែលការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ មានមកលើឧស្សាហកម្មបដិសណ្ឋារកិច្ច ជាពិសេសមកលើបុគ្គលិក ។

កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយសក្រោមប្រធានបទ "ភាពធន់ និងការស្តារឡើងវិញនៃបុគ្គលិកក្នុងវិស័យបដិសណ្ឋារកិច្ចក្នុងខេត្តសៀមរាប ក្នុងអំឡុងពេល និងក្រោយពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩" ត្រូវបានរៀបចំឡើង ដើម្បីកំណត់ពីបញ្ហានានា ដែលប៉ះពាល់ដល់សហគ្រាសដែលផ្តល់សេវាបដិសណ្ឋារកិច្ច និងបុគ្គលិកក្នុងអំឡុងពេលដែលមានជំងឺកូវីដ-១៩ ការអនុវត្តអន្តរាគមន៍នានា និងផែនការស្តារវិស័យទេសចរណ៍ឡើងវិញ។

## សង្ខេបលទ្ធផលនៃកិច្ចពិភាក្សា

វិស័យបដិសណ្ឋារកិច្ចក្នុងខេត្តសៀមរាប ទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ វិបត្តិនេះបានប៉ះពាល់ដល់បុគ្គលិកប្រមាណ ១១.៥១៤ នាក់ ដែលធ្វើការក្នុងវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប។ ដោយសារបាត់បង់ការងារ និងប្រាក់ចំណូល បុគ្គលិកមួយចំនួន បានចាកចេញពីខេត្តសៀមរាបទៅស្វែងរកឱកាសរកចំណូលនៅតាមខេត្តក្រុងដទៃទៀត។ បុគ្គលិកមួយចំនួនបានងាកទៅប្រកបរបរកសិកម្ម ដើម្បីចិញ្ចឹមជីវិត ប៉ុន្តែពួកគេជាច្រើននាក់ជួបការលំបាកត្បិតពួកគេមិនធ្លាប់មានជំនាញធ្វើកសិកម្ម។ជាលទ្ធផលបច្ចុប្បន្ននេះ វិស័យបដិសណ្ឋារកិច្ចនៅតែជួបការលំបាក ដោយសារបុគ្គលិកជាច្រើននាក់បានចាកចេញពីវិស័យនេះពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ហើយពុំបានវិលត្រឡប់មកវិញឡើយ។ ម្យ៉ាងវិញទៀត ក៏មានភោជនីយដ្ឋានតូចៗ និងហាងបៀហ្គាឌិនជាច្រើន កំពុងបើកដំណើរការផងដែរ។

បើទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ បុគ្គលិកដែលរងផលប៉ះពាល់ជាច្រើននាក់បានបង្ហាញពីភាពធន់របស់ខ្លួន។ ពួកគេ បានលើកឡើងថា ពួកគេបានស្វែងរកដំណោះស្រាយដោយខ្លួនឯងដោយមិនរង់ចាំការឧបត្ថម្ភពីរដ្ឋាភិបាលឡើយ។ពួកគេមួយចំនួនប្រៀបធៀបស្ថានភាពកូវីដ-១៩ ជាមួយនឹងជំនាន់ខ្មែរក្រហម ដែលជាការរំលឹកប្រាប់ខ្លួនឯងថា ប្រជាពលរដ្ឋអាចរស់បាន មិនថាកាលៈទេសៈលំបាកលំបិនយ៉ាងណានោះឡើយ។ ចំណុចនេះត្រូវបានឆ្លុះបញ្ចាំង តាមរយៈចំនួនបុគ្គលិកក្នុងវិស័យទេសចរណ៍ដែលរងផលប៉ះពាល់ ដូចជា បុគ្គលិកជួរមុខ ដែលជាអ្នកធ្វើការងារដោយដៃ និងទទួលបានប្រាក់ឈ្នួលប្រចាំថ្ងៃ រួមមាន ការងារសំណង់ ការងារដឹកជញ្ជូនអាហារ ការងារតាមផ្ទះជាដើម។ល។ បុគ្គលិកមួយចំនួនក៏ផ្តោតការយកចិត្តទុកដាក់លើសុខភាពផ្លូវចិត្តរបស់ពួកគេ តាមរយៈការធ្វើសកម្មភាពនានា ដូចជា ការធ្វើលំហាត់ប្រាណ សមាធិ ជិះកង់ បោះដុំ ឬច្រៀងខារ៉ាអូខេជាដើម។

ការរីករាលដាលនៃជំងឺកូវីដ-១៩ ផ្តល់នូវមេរៀនបទពិសោធន៍ដ៏ល្អមួយសម្រាប់អ្នកដែលចូលរួមពាក់ព័ន្ធក្នុងឧស្សាហកម្មទេសចរណ៍ ដូចជា រដ្ឋាភិបាល សហគ្រាសក្នុងវិស័យទេសចរណ៍ ព្រមទាំងបុគ្គលិក។ ជាការសំខាន់ណាស់ដែលអ្នកពាក់ព័ន្ធទាំងនេះ ត្រូវត្រៀមថវិកាឆ្លើយតបចំពោះ

វិបត្តិដែលកើតមានភ្លាមៗបែបនេះ។ ក្រៅពីថវិកាត្រៀមបម្រុង ម្ចាស់សហគ្រាសក្នុងវិស័យទេសចរណ៍ គួរមានផែនការអាជីវកម្មបម្រុង ឬធ្វើពិពិធកម្មអាជីវកម្មរបស់ខ្លួន។ ដោយឡែក បុគ្គលិកក្នុងវិស័យទេសចរណ៍ ក៏គួរមានប្រាក់សន្សំ និងរៀនសូត្រជំនាញទុកបម្រុង ដើម្បីឱ្យពួកគេអាចបំពេញការងារក្រៅពីវិស័យទេសចរណ៍ដើម្បីជួយជីវភាពរស់នៅក្នុងអំឡុងពេល ដែលមានវិបត្តិកើតឡើង។

## វាគ្មិន និងអ្នកសម្របសម្រួល

### អ្នកសម្របសម្រួល



លោកបណ្ឌិត ធួន ទ្រី
អ្នកស្រាវជ្រាវជាន់ខ្ពស់
នៃមជ្ឈមណ្ឌលខេមរសិក្សា

### វាគ្មិនកិត្តិយស



លោក ង៉ូវ សេងកាក់
ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប



លោក ឌុច សារ៉េត
អនុប្រធាន
សមាគមទេសចរណ៍កម្ពុជា



អ្នកស្រីបណ្ឌិត អ៊ឹម សុខសម្ផស្ស
អ្នកស្រាវជ្រាវ
នៃមជ្ឈមណ្ឌលខេមរសិក្សា



# ការស្វែងយល់អំពី សុខុមាលភាពសង្គម បណ្ដាញសង្គម និង ពលកម្មកុមារ ទាក់ទងការធ្វើចំណាកស្រុក ពីប្រទេសកម្ពុជា ទៅកាន់ប្រទេសថៃ ក្នុងបរិបទកូវីដ-១៩



ពលករចំណាកស្រុកកម្ពុជា ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ត្រូវបានប៉ាន់ស្មានថាមានចំនួនស្មើនឹង ៩២% នៃពលរដ្ឋខ្មែរ ១,២ លាននាក់ ដែលកំពុងធ្វើការនៅក្រៅប្រទេស។[13] ពលករទាំងនេះធ្វើចំណាកស្រុកទៅកាន់ប្រទេសថៃ ព្រោះពួកគេមានបំណងចង់ស្វែងរកឱកាសការងារថ្មីៗនៅតាមព្រំដែនថៃ និងដោយសារភាពក្រីក្រ និងកង្វះឱកាសការងារនៅកម្ពុជា។ ក្រុមងាយរងគ្រោះមួយចំនួនធំ ធ្វើការងារក្នុងលក្ខខណ្ឌលំបាក និងទទួលរងការកេងប្រវ័ញ្ចន៍នៅតាមច្រកដែលពួកគេប្រើប្រាស់សម្រាប់ធ្វើចំណាកស្រុករាប់ទសវត្សរ៍មកហើយ ដែលរួមមានការប្រឈមនឹងការជួញដូរមនុស្ស។ ស្ថានភាពរបស់ជនចំណាកស្រុក ទាំងនៅប្រទេសថៃ និងនៅប្រទេសកម្ពុជា ដែលជាប្រទេសកំណើតរបស់ពួកគេ កាន់តែមានស្ថានភាពយ៉ាប់យ៉ឺនទៅៗ ចាប់តាំងពីមានការរីករាលដាលនៃជំងឺកូវីដ-១៩មក។ ដោយហេតុថាអាជីវកម្មមួយចំនួនត្រូវបិទទ្វារ បន្ទាប់ពីរដ្ឋាភិបាលថៃអនុវត្តវិធានការឆ្លើយតបចំពោះជំងឺកូវីដ-១៩ អត្រាជនចំណាកស្រុកដែលបានវិលត្រឡប់មកកាន់កម្ពុជាវិញ នៅក្នុងរយៈពេលនៃការសិក្សានេះ មានការកើនឡើង ហើយពួកគេប្រឈមមុខខ្ពស់នឹងការឆ្លងជំងឺកូវីដ-១៩ ក្នុងអំឡុងពេលដែលពួកគេវិលត្រឡប់មកវិញ និងពុំមានការរ៉ាប់រងឬផ្ដល់ការគាំទ្រផ្នែកគាំពារសង្គមអ្វីសោះឡើយ។ បើតាមការិយាល័យរដ្ឋបាលខេត្តបាត់ដំបង ក្នុងចំណោមជនចំណាកស្រុកដែលបានវិលត្រឡប់មកកម្ពុជាវិញ ចន្លោះពីខែមេសា ដល់ខែមិថុនា ឆ្នាំ ២០២១ ចំនួន ៤.៦៧០ នាក់ (ស្រី ២.០៥៨ នាក់) មាន ៥១០ នាក់ (ស្រី ២៦១ នាក់) បានឆ្លងជំងឺកូវីដ-១៩។

---

13 https://www.khmertimeskh.com/501032136/more-than-one-million-cambodians-work-abroad-and-sent-about-3-billion-every-year-to-their-families/

ការអូសបន្លាយពេលនៃវិបត្តិកូវីដ-១៩នៅអាស៊ីអាគ្នេយ៍ និងការបន្តជួបការលំបាកនៅតាមតំបន់ជនបទនៃប្រទេសកម្ពុជានាពេលបច្ចុប្បន្ន កំពុងបង្ខំឱ្យមនុស្សជាច្រើននាក់ជ្រើសរើសយកជម្រើសដ៏សែនលំបាកនេះ នោះគឺត្រូវធ្វើចំណាកស្រុកទៅប្រទេសថៃម្តងទៀត បើទោះជាពួកគេប្រឈមនឹងការឆ្លងជំងឺ និងមានឱកាសតិចតួចក្នុងការទទួលបានការងារសមរម្យក៏ដោយ។ បណ្តាញមេខ្យល់ កាន់តែមានភាពសកម្ម ហើយកំពុងតែបានឆ្លៀតឱកាសទាញយកផលប្រយោជន៍ពីលំហូរនៃការធ្វើចំណាកស្រុកមិនច្បាស់លាស់នេះក្នុងទិសដៅទាំងពីរ ពោលគឺទាំងមកកាន់ប្រទេសថៃ និងវិលត្រឡប់មកកម្ពុជាវិញ ដែលជាហេតុធ្វើឱ្យជនចំណាកស្រុក រឹតតែប្រឈមមុខជាមួយហានិភ័យនៃការជួញដូរមនុស្ស។ មានភស្តុតាងបានពីការនិយាយតៗគ្នាមួយចំនួនបង្ហាញថា កុមាររឹតតែច្រើននាក់ កំពុងធ្វើចំណាកស្រុកទៅរកការងារធ្វើ និងកំពុងធ្វើការ។

កិច្ចពិភាក្សាស្តីពី "ការស្វែងយល់អំពីសុខុមាលភាពសង្គមរបស់ពលករចំណាកស្រុក និងគ្រួសារនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ក្នុងអំឡុងពេលដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩" ត្រូវបានរៀបចំឡើង ដើម្បីរួមចំណែកស្វែងយល់ពីសុខុមាលភាពសង្គមរបស់ពលករចំណាកស្រុកនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ព្រមទាំងគ្រួសាររបស់ពួកគេដែលបន្តស្នាក់នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេល និងក្រោយពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ការពិភាក្សានេះក៏ពិនិត្យលើយុទ្ធសាស្ត្រដែលមានសក្តានុពល ដើម្បីបង្កើនការផ្តល់ជំនួយសង្គមដល់ពលករចំណាកស្រុក ដែលបានធ្វើមាតុភូមិនិវត្តន៍ ព្រមទាំងគ្រួសាររបស់ពួកគេ។

## សង្ខេបលទ្ធផលនៃកិច្ចពិភាក្សា

ការស្រាវជ្រាវដែលធ្វើឡើងដោយមជ្ឈមណ្ឌលសម្រាប់ការវិភាគបញ្ហាអភិវឌ្ឍន៍ (ADIC) នៅកម្ពុជា បានបង្ហាញថាបញ្ហាសំខាន់ៗដែលពលករចំណាកស្រុកនៅក្នុងតំបន់គោលដៅទាំង ៤ នៃការសិក្សានេះជួបប្រទះ រួមមានការខ្វះឱកាសការងារសមរម្យនៅតាមមូលដ្ឋានរបស់ពួកគេ ការជាប់បំណុលកាន់តែច្រើនជាមួយធនាគារនិងអ្នកចងការប្រាក់ឯកជន ការរកចំណូលបានតិចតួចពីការធ្វើស្រែចំការដោយសារទិន្នផលស្រូវបានតិច និងការរកចំណូលមិនបានច្រើនពីមុខរបរតូចតាច។ ជនចំណាកស្រុក ក៏បានលើកឡើងផងដែរថា ពួកគេពឹងផ្អែកលើព័ត៌មានដែលបានពីមិត្តភ័ក្រ្ត និងគ្រួសារ ដើម្បីយកមកធ្វើការសម្រេចចិត្តក្នុងការធ្វើចំណាកស្រុករបស់ពួកគេ។

ពលករចំណាកស្រុក បានប្រើប្រាស់មធ្យោបាយជាច្រើនផ្សេងៗ ដើម្បីផ្ញើរប្រាក់នៅឱ្យគ្រួសាររបស់ពួកគេនៅស្រុកកំណើតនៅកម្ពុជា។ ពួកគេបានលើកឡើងថា ពួកគេអាចយកលុយមកតាមខ្លួន (ចន្លោះពី ១៥០ ដល់ ២៥០ ដុល្លារ) មកឱ្យគ្រួសារនៅពេលដែលពួកគេវិលត្រឡប់មកស្រុកកំណើតវិញ ផ្ញើរប្រាក់តាមរយៈធនាគារថៃ ផ្ញើរប្រាក់តាមវីង ឬប្រើប្រាស់មេខ្យល់។

ពលករចំណាកស្រុកឧស្សាហ៍ទំនាក់ទំនងមកកាន់គ្រួសារតាមរយៈការហៅទូរស័ព្ទ និងកម្មវិធីផ្ញើរសារតាមហ្វេសប៊ុក (Facebook Messenger)។ ទោះជាយ៉ាងនេះក្តី អ្នកឆ្លើយតបមួយចំនួនបានលើកឡើងថា ពួកគេមិនចេះប្រើប្រាស់ហ្វេសប៊ុកឡើយ ដូច្នេះពួកគេទំនាក់ទំនងជាមួយគ្រួសារតាមទូរស័ព្ទម្តងម្កាលតែប៉ុណ្ណោះ។ ក្នុងអំឡុងពេលដែលមានការរីករាលដាលនៃ

ជំងឺកូវីដ-១៩ ពលករចំណាកស្រុកមួយចំនួនក៏បានលើកឡើងថា ពួកគេមានអារម្មណ៍កណ្តោចកណ្តែង និងមានការបារម្ភពីកូនៗរបស់ពួកគេ។

មានការទទួលស្គាល់ជាទូទៅថាជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់ដល់ការងាររបស់ពលករចំណាកស្រុកនៅក្នុងប្រទេសថៃ។ ការបាត់បង់ការងារបានបង្កផលប៉ះពាល់ផ្ទាល់លើប្រាក់ចំណូលរបស់ពលករ និងក្រុមគ្រួសាររបស់ពួកគេ។ ខណៈពេលដែលពលករចាំបាច់ត្រូវចំណាយលើម្ហូបអាហារជារៀងរាល់ថ្ងៃ បើទោះជាពួកគេពុំមានការងារធ្វើក៏ដោយ ពួកគេមួយចំនួនបានលើកឡើងថា ពួកគេបានទទួលការឧបត្ថម្ភពីពលករចំណាកស្រុកដទៃទៀត សមាគមខ្មែរនៅក្នុងប្រទេសថៃដែលជាសមាគមក្រៅផ្លូវការ អង្គការសប្បុរសធម៌ និងក្រុមហ៊ុនថៃ ដែលចែកអាហារ អង្ករ មី ទឹកស៊ីអ៊ីវ ស៊ុត និងត្រីខកំប៉ុង ដល់ពលករចំណាកស្រុក ពេលដែលពួកគេត្រូវបិទខ្ទប់ឱ្យស្នាក់នៅតាមបន្ទប់ជួល។ ការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏បង្កផលប៉ះពាល់អវិជ្ជមានមកលើលទ្ធភាពសងបំណុលនៅស្រុកកំណើត ក៏ដូចជា ការរ៉ាប់រងចំណាយនានា នៅពេលដែលពួកគេរត់ឯកសារទៅធ្វើការនៅក្នុងប្រទេសថៃ។

និយាយជារួម ពលករចំណាកស្រុកដែលមានឯកសារស្របច្បាប់ ច្រើនតែធ្វើដំណើរទៅស្រុកកំណើតវិញពីរដងក្នុងមួយឆ្នាំ ដើម្បីប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ និងចូលឆ្នាំខ្មែរ។ ពលករចំណាកស្រុកដែលមានឯកសារស្របច្បាប់ ចូលមកក្នុងប្រទេសថៃដោយស្របច្បាប់ និងធ្វើដំណើរទៅស្រុកកំណើតវិញដោយមិនចាំបាច់ប្រើប្រាស់មេខ្យល់ឡើយ ប៉ុន្តែពួកគេត្រូវចំណាយប្រាក់ចន្លោះពី ៨០ ទៅ ១០០ ដុល្លារសម្រាប់ការធ្វើដំណើរ ការហូបចុក។ល។ នៅពេលដែលពួកគេធ្វើដំណើរត្រឡប់មកផ្ទះវិញ។ អ្នកឆ្លើយតបមួយចំនួនបានលើកឡើងថា ប្រសិនបើពួកគេត្រូវវិលត្រឡប់មកស្រុកកំណើត ក្នុងអំឡុងពេលដែលមានការអនុវត្តវិធានការបិទខ្ទប់ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ពួកគេត្រូវចំណាយប្រាក់ចន្លោះពី ២០០ ដល់ ២៥០ ដុល្លារឱ្យមេខ្យល់នាំពួកគេមកផ្ទះវិញ។

ការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដាក់សម្ពាធមកលើលទ្ធភាពរបស់ពលករចំណាកស្រុកក្នុងការរ៉ាប់រងលើចំណាយថែទាំសុខភាពនៅក្រៅប្រទេសផងដែរ។ នៅក្នុងប្រទេសថៃ ពលករចំណាកស្រុកដែលមានឯកសារសម្គាល់ខ្លួនត្រឹមត្រូវ ត្រូវទិញសេវាធានារ៉ាប់រងសុខភាពប្រមាណជា ១៥ ដុល្លារក្នុងមួយខែ។ លើសពីនេះ ពួកគេត្រូវបង់ប្រាក់ប្រហែលជា ៣៥ ដុល្លារ ដើម្បីទទួលបានវ៉ាក់សាំងកូវីដ-១៩ ដូសទី១។ នៅកម្ពុជា ពលករចំណាកស្រុកដែលពុំមានប័ណ្ណក្រីក្រ ឬដែលឆ្លងជំងឺកូវីដ-១៩ ត្រូវបង់ប្រាក់ចន្លោះពី ០,៥ ដុល្លារទៅ ០,៧៥ ដុល្លារលើសេវាសុខភាព និង ២០ ដុល្លារទៀតទៅឱ្យកន្លែងផ្តល់ការព្យាបាល ដោយមិនរាប់បញ្ចូលសេវាថែទាំសុខភាព និងថ្លៃឱសថឡើយ។ នៅតាមច្រកព្រំដែន មានការចែកម៉ាស់ដល់ពលករចំណាកស្រុកដែលបានធ្វើមាតុភូមិនិវត្តន៍ ការធ្វើតេស្តរកកូវីដ-១៩ និងការនាំពួកគេទៅកាន់មណ្ឌលចត្តាឡីស័ក។ ពួកគេបានទទួលអាហារ ៣ ពេលក្នុងមួយថ្ងៃ មុងភួយខ្នើយ កញ្ចប់អនាម័យ ការពិនិត្យសុខភាពប្រចាំថ្ងៃ និងការដឹកជញ្ជូនដោយមិនគិតថ្លៃពីមណ្ឌលចត្តាឡីស័កទៅស្រុកកំណើតវ បន្ទាប់ពីរយៈពេល ១៤ ថ្ងៃ។

ក្នុងករណីដែលពួកគេធ្វើតេស្តរកឃើញថាបានឆ្លងជំងឺកូវីដ-១៩ ពួកគេបានទទួលការព្យាបាលដោយមិនគិតថ្លៃ។

ដើម្បីបង្កើនការឧបត្ថម្ភជំនួយសង្គមដល់ពលករចំណាកស្រុកដែលបានធ្វើមាតុភូមិនិវត្តន៍ ក៏ដូចជា ក្រុមគ្រួសាររបស់ពួកគេ ជាអនុសាសន៍៖

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារណ្ដុះបណ្ដាល និងវិជ្ជាជីវៈ គួរផ្ដល់ការគាំទ្រដល់បណ្ដាញពលករក្រៅផ្លូវការ ដែលកំពុងមានសិទ្ធិរួចទៅហើយនៅក្នុងប្រទេសថៃ ដើម្បីឱ្យពួកគេអាចមានសមត្ថភាពពេញលេញជួយដល់ពលករចំណាកស្រុកដែលងាយរងគ្រោះឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។
- អាជ្ញាធរថ្នាក់ក្រោមជាតិ គួរផ្ដល់ព័ត៌មានដល់ពលករចំណាកស្រុកអំពីនីតិវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមតម្រូវការ។
- កម្មវិធីជំនួយសង្គម ដែលស្ថិតក្រោមក្របខណ្ឌគាំពារសង្គម គួរអនុវត្តក្នុងលក្ខណៈជាប្រព័ន្ធ និងគួរមានការផ្ដល់កម្មវិធីជំនួយសង្គមដល់ពលករចំណាកស្រុក និងគ្រួសាររបស់ពួកគេ។
- ក្រសួងមហាផ្ទៃគួរសហការជាមួយរដ្ឋាភិបាលថៃ និងអាជ្ញាធរនៅតាមព្រំដែន ដើម្បីសម្របសម្រួលការផ្ដល់ឯកសារស្របច្បាប់ដើម្បីជានាភាពស្របច្បាប់របស់ពលករចំណាកស្រុកកម្ពុជាឱ្យធ្វើការក្នុងប្រទេសថៃក្រោយពេលដែលស្ថានភាពជំងឺកូវីដ-១៩ បានធូរស្បើយ។

## វាគ្មិន និងអ្នកសម្របសម្រួល

អ្នកសម្របសម្រួល



លោក អឿ អ៊ីល
នាយកប្រតិបត្តិ
នៃមជ្ឈមណ្ឌលសម្រាប់
ការវិភាគបញ្ហា អភិវឌ្ឍន៍



លោកជំទាវ ប៉ុក ណាឌី
អភិបាលរង ខេត្តពោធិ៍សាត់

វាគ្មិនកិត្តិយស



លោក អ៊ិន សុផល្លា
អភិបាលរងនៃគណៈអភិបាលស្រុកកណ្ដៀង ខេត្តពោធិ៍សាត់



លោកស្រី ឡូវ សំណាន
នាយិកាប្រតិបត្តិ
នៃអង្គការអភិវឌ្ឍន៍នារីខ្មែរ



លោក និល តំណាង
អ្នកស្រាវជ្រាវ
នៃមជ្ឈមណ្ឌលសម្រាប់
ការវិភាគបញ្ហាអភិវឌ្ឍន៍

# ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើការអប់រំរបស់ជនមានពិការភាពនៅកម្ពុជា



នៅកម្ពុជា ជនមានពិការភាពមានចំនួន ៦៨៩.៥៣២ នាក់ ដែលក្នុងនោះ ៧៤,៣% មានពិការភាពកម្រិតស្រាល ១៩,៤% មានពិការភាពធ្ងន់ធ្ងរ និង ៦,៣% មានពិការភាពធ្ងន់ធ្ងរដែលមិនអាចធ្វើអ្វីបាន។[14] ជនមានពិការភាពបានទទួលការការពារពីអនុសញ្ញាអន្តរជាតិ និងច្បាប់ក្នុងប្រទេស ក្នុងគោលបំណងធានាយ៉ាងណាឱ្យពួកគេអាចទទួលបានសិទ្ធិ និងសេរីភាពពេញលេញរួមមាន សិទ្ធិមិនទទួលបានការរើសអើង សិទ្ធិចូលរួមប្រកបដោយបរិយាបន្នក្នុងសង្គម ការទទួលបានឱកាស សិទ្ធិទទួលបានផាសុកវត្ត និងការប្រតិបត្តិដោយស្មើភាពគ្នា ក៏ដូចជាទទួលបានការគោរព និងសេចក្ដីថ្លៃថ្នូរក្នុងនាមជាមនុស្ស។[15]

សិទ្ធិទទួលបានការអប់រំរបស់ជនមានពិការភាពបានទទួលការការពារ និងត្រូវបានដាក់ចេញនៅក្នុង លិខិតូបករណ៍ដទៃទៀតដូចជាអនុសញ្ញាស្ដីពីសិទ្ធិជនពិការរបស់អង្គការសហប្រជាជាតិ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្ដីពីការការពារនិងលើកកម្ពស់សិទ្ធិជនពិការនៅកម្ពុជា។ សិទ្ធិជនមានពិការភាពត្រូវបានលើកកម្ពស់ តាមរយៈគោលនយោបាយនានា ដូចជាយុទ្ធសាស្ត្រជាតិស្ដីពីជនមានពិការភាព ២០១៩-២០២៣ ជាដើម។ ពាក់ព័ន្ធនឹងការលើកកម្ពស់ការអប់រំសម្រាប់ជនមានពិការភាពនៅកម្ពុជាវិញ រាជរដ្ឋាភិបាលកម្ពុជាបានផ្ដោតការយកចិត្តទុក

---

14 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ជំរឿនប្រជាជនទូទៅនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ របាយការណ៍លទ្ធផលចុងក្រោយ ខែតុលា ឆ្នាំ២០២០ ទំព័រ១២៥។

15 សូមមើលអនុសញ្ញា ILO ស្ដីពីការស្ដារនីតិសម្បទាវិជ្ជាជីវៈ និងការងារ (សម្រាប់ជនពិការ) (លេខ ១៥៩) ឆ្នាំ១៩៨៣។ អនុសញ្ញាសហប្រជាជាតិស្ដីពីសិទ្ធិជនពិការ អនុម័តនៅ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ និងច្បាប់ស្ដីពីការការពារ និងលើកកម្ពស់សិទ្ធិជនពិការ របស់កម្ពុជា ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩។

ដាក់លើការអប់រំពិសេស តាមរយៈការអនុម័តលើគោលនយោបាយស្តីពីការអប់រំសម្រាប់កុមារមានពិការភាពកាលពីឆ្នាំ២០០៨ ហើយក្រោយមកក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលដើម្បីបង្កើតជាគោលនយោបាយស្តីពីការអប់រំបរិយាបន្ននៅក្នុងឆ្នាំ២០១៨។

ការផ្ទុះជំងឺកូវីដ-១៩នៅកម្ពុជាចាប់តាំងពីដើមឆ្នាំ២០២០មក បានបង្កឱ្យមានវិបត្តិសុខភាពសាធារណៈ និងការលំបាកផ្នែកសង្គម និងសេដ្ឋកិច្ចដល់ប្រជាពលរដ្ឋ អាជីវកម្ម និងរដ្ឋាភិបាល។ វិបត្តិនេះមិនលើកលែងឱ្យជនមានពិការភាពឡើយ ព្រោះការងារនានារបស់ពួកគេ ត្រូវបានផ្អាក ឬបញ្ចប់ដោយសារការព្យួរ ឬការបិទអាជីវកម្ម ការអនុវត្តវិធានការរក្សាគម្លាតសង្គម ការរឹតត្បិតលើការធ្វើដំណើរ ការរឹតត្បិតលើការជួបជុំគ្នា ការអនុវត្តវិធានការបិទខ្ទប់ ការបិទសាលារៀន និងវិធានការទប់ស្កាត់ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ដទៃទៀត ដែលទំនងជាបង្កផលប៉ះពាល់ដល់សិទ្ធិ និងអត្ថប្រយោជន៍របស់ជនមានពិការភាពដែលត្រូវបានធានានៅក្នុងច្បាប់។ ជំងឺកូវីដ-១៩ ក៏បង្កផលប៉ះពាល់ដល់ការអប់រំផងដែរ ដែលអាចបង្កជាឧបសគ្គដល់ការសម្រេចគោលដៅអភិវឌ្ឍដោយចីរភាពទី៤។ ក្នុងវិស័យអប់រំវិញ សិស្សមានពិការភាព ត្រូវបានរកឃើញថារងផលប៉ះពាល់រឹតតែធ្ងន់ធ្ងរទៅទៀត ក្នុងការរស់នៅ និងការអប់រំរបស់ពួកគេ។

ការពិភាក្សានេះមានគោលបំណងស្វែងយល់ពីផលប៉ះពាល់ដែលជំងឺកូវីដ-១៩ ដែលមានលើសិស្សមានពិការភាព និងការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីជួយដល់សិស្សមានពិការភាពក្នុងអំឡុងដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩។

## សង្ខេបលទ្ធផលនៃកិច្ចពិភាក្សា

ជនមានពិការភាពទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរខុសពីអ្នកដទៃទៀត នៅពេលដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩។ បើតាមការសិក្សានេះ សិស្សមានពិការភាពមានអារម្មណ៍ថា បានរងផលប៉ះពាល់ធ្ងន់ធ្ងរជាងសិស្សដែលពុំមានពិការភាព។ សុខុមាលភាពផ្លូវចិត្ត គុណភាពនៃការអប់រំ និងឥរិយាបថរបស់មាតាបិតា របស់សិស្សដែលខ្សោយគំហើញ និងខ្សោយការស្តាប់ ត្រូវបានរកឃើញថា បានរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩។ សិស្សដែលមានពិការភាពក៏បានលើកឡើងផងដែរថា ពួកគេត្រូវនៅឯកាពីមិត្តភ័ក្រ្ត ហើយការដែលពុំមានសេវាជួយដល់ជនមានពិការភាព ក៏បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើសុខុមាលភាពរបស់ពួកគេផងដែរ។ លើសពីនេះ ដោយសារតែការរីករាលដាលនៃជំងឺកូវីដ-១៩ កើតឡើងភ្លាមៗ សាលារៀននានាពុំបានត្រៀមខ្លួនក្នុងការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងបរិយាបន្នឱ្យបានលឿននោះឡើយ ហើយការបិទទ្វារសាលារៀន និងការរៀនសូត្រតាមប្រព័ន្ធអនឡាញ ក៏បានបង្កផលប៉ះពាល់ដល់ការរៀនសូត្ររបស់សិស្ស ដោយសារតែពុំមានបច្ចេកវិទ្យាសម្រាប់ផ្តល់ជាជំនួយ វិធីសាស្រ្តបង្រៀនដែលមានលក្ខណៈបរិយាបន្ន និងការភ្ជាប់បណ្តាញអ៊ីនធឺណិតដែលមានដំណើរការល្អ។ មានការរាយការណ៍ថា ឪពុកម្តាយសិស្ស បានផ្តល់អាទិភាពដល់កូនពុំមានពិការភាពក្នុងការប្រើប្រាស់ឧបករណ៍វៃឆ្លាត ក្នុងករណីដែលពួកគេមានធនធានតិចតួច ។

ការរីករាលដាលនៃជំងឺកូវីដ-១៩កើតឡើង ដោយគេមិនបានរំពឹងទុកជាមុន ហើយក៏ពុំមាននរណាបានត្រៀមខ្លួននោះដែរ។ ក្រោយពេលដែលសាលារៀនបានទទួលការជូនដំណឹងពីរដ្ឋាភិបាល សាលារៀនបារម្ភថាតើគ្រូអាចបង្រៀនសិស្សឬទេ។ ប៉ុន្តែជាការឆ្លើយតបចំពោះមុខ សាលារៀនបានស្នើសុំឱ្យគ្រូប្រើប្រាស់តេឡេក្រាម ដើម្បីផ្ញើឯកសារទៅឱ្យសិស្ស។ កម្មវិធី Zoom ក៏ត្រូវបានប្រើប្រាស់សម្រាប់ការបង្រៀនដែរ ប៉ុន្តែពុំមានសិស្ស មាតាបិតា ឬសូម្បីតែគ្រូជាច្រើននាក់ដឹងពីរបៀបប្រើប្រាស់បច្ចេកវិទ្យានេះឡើយ។

សិស្សនៅតាមទីក្រុង ឬតំបន់ប្រជុំជន អាចចាប់ផ្តើមប្រើប្រាស់បច្ចេកវិទ្យាថ្មីបានយ៉ាងលឿន ប៉ុន្តែសិស្សដែលរស់នៅតាមតំបន់ជនបទ មានការលំបាកក្នុងការប្រើប្រាស់បច្ចេកវិទ្យា ដូចជា ការភ្ជាប់អ៊ីនធឺណិតពុំមានស្ថេរភាព និងការមានចំណេះដឹងតិចតួចអំពីរបៀបប្រើប្រាស់បច្ចេកវិទ្យាថ្មីៗទាំងនេះ។ មានអង្គការតិចតួចប៉ុណ្ណោះដែលផ្តល់ការគាំទ្រក្នុងរយៈពេលនេះ ដូចជា ផ្តល់ជាឧបករណ៍វៃឆ្លាត រៀបចំសម្ភារៈឯកសារ និងការឧបត្ថម្ភផ្សេងទៀតជាដើម។ ប៉ុន្តែ សិស្សដែលខ្សោយការស្តាប់ និងគំហើញ ជួបនឹងការលំបាកក្នុងការសិក្សាតាមប្រព័ន្ធអនឡាញ ព្រោះឯកសារទាំងនេះត្រូវការកែសម្រួលបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ។ ករណីអ្នកគ្រូម្នាក់ដែលមានពិការភាពភ្នែក ក៏ត្រូវបានលើកឡើងផងដែរ។ គាត់ជួបការលំបាកក្នុងការផ្លាស់ទីក្នុងអំឡុងពេលដែលមានការអនុវត្តវិធានការរឹតបន្តឹងការធ្វើដំណើរ និងមានអារម្មណ៍ធ្លាក់ទឹកចិត្តផងដែរ ដោយសារតែគាត់ជាមនុស្សពិការភ្នែក ហើយចាំបាច់ត្រូវនៅក្នុងផ្ទះគ្រប់ពេលវេលាទាំងអស់។ គាត់ក៏ជួបការលំបាកមួយចំនួនក្នុងការបង្រៀនផងដែរ។ គាត់បានលើកឡើងថា កម្មវិធី Google Platform សម្រាប់ការបង្រៀនពុំបានផ្តល់ភាពងាយស្រួលដល់ជនពិការភ្នែកឡើយ។ ការចំណាយលើជីវភាពរស់នៅ ក៏ក្លាយជាបញ្ហាមួយទៀតសម្រាប់គាត់ និងសិស្សមានពិការភាពផងដែរ។

សិស្សមានពិការភាព ក៏ជួបប្រទះនឹងការរើសអើង ការរើសអើងពីសិស្សផ្សេងទៀត និងពីគ្រូផងដែរ។ ចាំបាច់ត្រូវមានការបណ្តុះបណ្តាលឱ្យបានកាន់តែប្រសើរអំពីការអប់រំបរិយាបន្ន ដើម្បីជួយកសាងបរិយាកាសក្នុងសាលារៀនឱ្យមានសុវត្ថិភាព និងផ្តល់នូវភាពកក់ក្តៅ។ ការផ្តល់អនុសាសន៍ជាច្រើនចេញពីការពិភាក្សានេះ ចាំបាច់ត្រូវមាន។ ការប្រើប្រាស់បច្ចេកវិទ្យាផ្តល់ជំនួយដើម្បីធានាថាសិស្សដែលមានតម្រូវការពិសេស អាចរៀននៅក្នុងបន្ទប់រៀនផង និងតាមប្រព័ន្ធអនឡាញផង។ ចាំបាច់ត្រូវមានការផ្តល់ការបណ្តុះបណ្តាលដល់គ្រូ ដើម្បីធានាថាការបង្រៀនដោយផ្ទាល់ និងការបង្រៀនតាមប្រព័ន្ធអនឡាញ មានលក្ខណៈបរិយាបន្ន ហើយសិស្សដែលមានតម្រូវការពិសេស គួរដឹងពីស្ថានភាពដែលមានការប្រែប្រួល ដើម្បីឱ្យពួកគេអាចទទួលបានការគាំទ្រផ្លូវចិត្ត។

# វាគ្មិន និងអ្នកសម្របសម្រួល

## អ្នកសម្របសម្រួល



**លោក គីម វារ៉ា**

នាយក
នៃវិទ្យាស្ថានសិក្សាស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន
នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង



**លោកបណ្ឌិត ណុប កញ្ញារិទ្ធិ**

សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

## វាគ្មិនកិត្តិយស



**លោក ទុន ប៊ុនតង**

នាយករង
នៃវិទ្យាល័យអប់រំពិសេសសៀមរាប



**កញ្ញា សៀម ណារី**

សាស្ត្រាចារ្យ
នៃវិទ្យាល័យអប់រំពិសេសសៀមរាប



# កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយស៖ វិស័យសេវាសាធារណៈនៅកម្ពុជា

## គម្រោងប្រាក់សោធននិវត្តន៍សម្រាប់វិស័យឯកជននៅកម្ពុជា៖ ការត្រៀមខ្លួន និងផលប៉ះពាល់នៃសុខុមាលភាពសង្គម




នៅកម្ពុជា ប្រព័ន្ធគាំពារសង្គមកំពុងស្ថិតនៅក្នុងដំណាក់កាលទើបអភិវឌ្ឍនៅឡើយ។ សកម្មភាព និងគោលនយោបាយពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម ទើបតែលេចចេញជារូបរាង កាលពីឆ្នាំ២០១៧ ក្រោយពេលដែលក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជារួចមក។ ក្រោយពេលដែលគោលនយោបាយនេះត្រូវបានដាក់ចេញ មានការបង្កើតស្ថាប័នជាបន្តបន្ទាប់ ដូចជា ក្រុមប្រឹក្សាជាតិគាំពារសង្គម (NSPC) គណៈកម្មាធិការប្រតិបត្តិ (EXCO) និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម (GS-NSPC) ជាដើម។ ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវបានបង្កើតឡើង ក្នុងឆ្នាំ២០១៧ ក្នុងទម្រង់ជាស្ថាប័នធ្វើគោលនយោបាយ។ ក្នុងឆ្នាំ២០១៨ គណៈកម្មាធិការប្រតិបត្តិ ត្រូវបានបង្កើតឡើង ក្នុងទម្រង់ជាយន្តការសម្របសម្រួលរវាងកម្រិតនយោបាយ និងកម្រិតបច្ចេកទេស ដើម្បីគាំទ្រដល់ការបំពេញមុខងារ និងភារកិច្ចទាំងអស់របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ខណៈពេលដែលអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវបានបង្កើតឡើង ដើម្បីជួយគាំទ្រដល់ការងាររបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម និងគណៈកម្មាធិការប្រតិបត្តិ។

ជាមួយនឹងការបង្កើតនិយ័តករសន្តិសុខសង្គម ដែលបំពេញតួនាទីជាអាជ្ញាធរត្រួតពិនិត្យលើការធានាតម្លាភាព និងគណនេយ្យភាពនៃប្រតិបត្តិករសន្តិសុខសង្គម (SSR) និងជាមួយកិច្ចខិតខំប្រឹងប្រែងជាច្រើនរបស់រដ្ឋាភិបាលក្នុងការជំរុញដំណើរការរៀបចំសេដ្ឋកិច្ចឱ្យមានលក្ខណៈ

ក្នុងប្រព័ន្ធ នៅដំណាក់កាលបន្តបន្ទាប់ ចំនួនក្រុមហ៊ុន និងកម្មករនិយោជិតដែលបានចុះបញ្ជីនឹងមានការកើនឡើងជាបណ្តើរៗ។ នេះនាំឱ្យមានការកើនឡើងនូវចំនួនប្រាក់ភាគទានបង់ចូលក្នុងរបបសោធន ប្រាក់ភាគទានដែលប្រមូលបាននឹងត្រូវទុកក្នុងធនាគារ ដែលជួយពន្លឿនការប្រើប្រាស់សាច់ប្រាក់របស់ធនាគារក្នុងសេដ្ឋកិច្ច ការវិនិយោគលើទីផ្សារភាគហ៊ុននិងទីផ្សារបំណុល ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់ប្រទេស និង/ឬក្នុងវិស័យអចលនទ្រព្យជាដើម។ល។ ការវិនិយោគទាំងនេះ នឹងសម្រួលដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ហើយនៅក្នុងរយៈពេលវែង នឹងបង្កើនសុខុមាលភាពរបស់ប្រជាពលរដ្ឋ តាមរយៈការទទួលបានប្រាក់សោធន ក្រោយពេលចូលនិវត្តន៍។ ការអនុវត្តរបបសោធនសម្រាប់វិស័យឯកជនបានចាប់ផ្តើមកាលពីខែតុលា ឆ្នាំ ២០២២ ជាមួយនឹងអត្រាភាគទានស្មើនឹង ៤% នៃប្រាក់ឈ្នួលគោល ដែលក្នុងនោះ ២% ត្រូវបង់ដោយនិយោជក និង ២% ទៀតត្រូវបង់ដោយនិយោជិត។ ទោះជាយ៉ាងនេះក្តី ជោគជ័យនៃការអនុវត្តរបបសោធនបែបនេះ នៅជាមន្ទិលនៅឡើយ។

កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយសស្តីពី "គម្រោងប្រាក់សោធននិវត្តន៍សម្រាប់វិស័យឯកជននៅកម្ពុជា៖ ការត្រៀមខ្លួន និងផលប៉ះពាល់នៃសុខុមាលសង្គម" ត្រូវបានធ្វើឡើង ដើម្បីស្វែងយល់ពីការយល់ដឹង ការយល់ឃើញ និងប្រតិកម្មរបស់របស់សាធារណៈជន ចំពោះការដាក់ឱ្យអនុវត្តនូវរបបសោធនសម្រាប់វិស័យឯកជននៅកម្ពុជា។ ការពិភាក្សានេះ ក៏ផ្តោតលើការត្រៀមខ្លួនរបស់និយោជក និងនិយោជិតសម្រាប់ការអនុវត្តរបបនេះ បញ្ហាប្រឈម និងអត្ថប្រយោជន៍សក្តានុពលនៃរបបនេះ ព្រមទាំងជម្រើសគោលនយោបាយនានា ដើម្បីឱ្យរដ្ឋាភិបាលយកមកធ្វើការពិចារណា។

## សង្ខេបលទ្ធផលនៃកិច្ចពិភាក្សា

លទ្ធផលដែលទទួលបានពីការអង្កេតនេះ បង្ហាញថានិយោជិត និងនិយោជក ដែលត្រូវបានសាកសួរភាគច្រើន បានដឹង និងបានត្រៀមខ្លួនសម្រាប់ការអនុវត្តរបបសោធន។ ភាគីទាំងពីរសុទ្ធតែទទួលស្គាល់ថារបបសោធនបំពេញតួនាទីយ៉ាងសំខាន់ ប៉ុន្តែក៏មានការបារម្ភពីការកើនឡើងនៃចំណាយប្រតិបត្តិការផងដែរ ត្បិតនិយោជកត្រូវចូលរួមបង់ភាគទានចូលទៅក្នុងរបបសោធន។ ទោះជាយ៉ាងនេះក្តី និយោជកដែលត្រូវបានសាកសួរភាគច្រើនពេញចិត្តជាមួយនឹងអត្រាបង់ភាគទានបច្ចុប្បន្ន ហើយមានឆន្ទៈ និងមានសមត្ថភាពបង់ភាគទាននេះសម្រាប់រយៈពេល ៥ ឆ្នាំទៅមុខទៀត។

ចំនួនប្រាក់ភាគទានសរុបដែលបង់ចូលរបបសោធន ត្រូវបានប៉ាន់ប្រមាណថាជាមធ្យមមានចំនួន ២១១,៧ លានដុល្លារពីឆ្នាំ ២០២២-២០២៦, ៥៧១,៣ លានដុល្លារពីឆ្នាំ ២០២៧-២០៣១ និងប្រមាណ ១.១៧៨,៧ លានដុល្លារពីឆ្នាំ ២០៣២-២០៣៥។ ការវិភាគប្រើប្រាស់ម៉ូដែលសេដ្ឋកិច្ច Computable General Equilibrium (CGE) បង្ហាញថាការអនុវត្តរបបសោធនសម្រាប់វិស័យឯកជន និងរួមចំណែកជាវិជ្ជមានដល់ការបង្កើតការងារ កំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស) និងការកាត់បន្ថយភាពក្រីក្រ។

បើទោះជាលទ្ធផលរកឃើញនេះ មានលក្ខណៈវិជ្ជមានក៏ដោយ ក៏មានការបារម្ភមួយចំនួនផងដែរ ពាក់ព័ន្ធនឹងការអនុវត្តរបបសន្តិសុខសង្គម ត្បិតនិយោជិកដែលបានសាកសួរ ហើយដែលបានចុះបញ្ជីជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ទទួលបានសេវាធានារ៉ាប់រងតែមួយប៉ុណ្ណោះ (ដូចជា របបថែទាំសុខភាព និងរបបគ្រោះថ្នាក់ការងារ) ខណៈពេលដែលនិយោជិតមួយចំនួនបានទទួលសេវាធានារ៉ាប់រងច្រើនមុខ។ លទ្ធផលរកឃើញនេះ ខុសពីអ្វីដែលមានចែងនៅក្នុងច្បាប់។ បើទោះជានិយោជកដែលត្រូវបានសាកសួរភាគច្រើន បានដឹងពីរបបសោធនក៏ដោយ មានតែ ២១% ប៉ុណ្ណោះ ដែលបានលើកឡើងថា ប.ស.ស គឺជាប្រភពព័ត៌មានសំខាន់ជាងគេ ដែលនេះបង្ហាញថា ប.ស.ស អាចបង្កើនការផ្សព្វផ្សាយព័ត៌មានឱ្យបានជ្រួតជ្រាបដល់ក្រុមគោលដៅបន្ថែមទៀត។ មានការបារម្ភមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងចាត់ចែងមូលនិធិនេះ ជាពិសេស ក្នុងអំឡុងពេលដែលសេដ្ឋកិច្ចកំពុងមានការធ្លាក់ចុះ។ ជាការឆ្លើយតបមួយផ្នែកចំពោះក្តីបារម្ភនេះ រដ្ឋាភិបាលបានបង្កើននិយ័តករសន្តិសុខសង្គម។ ការទទួលខុសត្រូវមួយក្នុងចំណោមការទទួលខុសត្រូវជាច្រើនរបស់និយ័តករសន្តិសុខសង្គម គឺផ្តល់ការណែនាំអំពីការយកមូលនិធិនេះទៅវិនិយោគ និងត្រួតពិនិត្យលើការសម្រេចចិត្តវិនិយោគ ដែលធ្វើឡើងដោយ ប.ស.ស។ ការវិនិយោគនឹងមានការធ្វើពិពិធកម្ម ដើម្បីធានានិរន្តរភាព និងភាពធន់នៃមូលនិធិនេះ។

ជាជំហានបន្ទាប់ រដ្ឋាភិបាល គួរពិចារណាអនុវត្តអនុសាសន៍ ដូចតទៅ។ ដំបូង បន្តពង្រឹកការគ្របដណ្តប់នៃរបបសោធន ហើយក្នុងពេលជាមួយគ្នា រក្សាការជឿទុកចិត្ត និងប្រសិទ្ធភាពនៃការគ្រប់គ្រងចាត់ចែងរបបនេះ។ ទី២ បង្កើនគុណភាព និងសមត្ថភាពគ្រប់គ្រងបច្ចុប្បន្នរបស់ ប.ស.ស ដើម្បីគ្រប់គ្រងចំនួនប្រាក់សោធន ដែលនឹងបន្តមានការកើនឡើងនាពេលអនាគតប្រកបដោយចីរភាព។ ទី៣ សហការឱ្យបានជិតស្និទ្ធជាមួយនិយោជក ដើម្បីកាត់បន្ថយបន្ទុកពីការចូលរួមបង់ភាគទានរបស់ពួកគេក្នុងរបបនេះ តាមរយៈការផ្តល់ជាការលើកទឹកចិត្តនៅក្នុងច្បាប់ និងបង្កើនផលិតភាព ក៏ដូចជា ធ្វើឱ្យបរិយាកាសធុរកិច្ចកាន់តែមានភាពប្រសើរ។ ចុងក្រោយ រដ្ឋាភិបាល គួរដាក់ចេញនូវក្របខណ្ឌនិយ័តកម្ម ដើម្បីធានាថាថវិកាប្រមូលបានពីរបបសោធន នឹងរួមចំណែកដល់ការវិនិយោគ ដែលផ្តល់ផលជាវិជ្ជមានត្រឡប់មកវិញ។

## វាគ្មិន និងអ្នកសម្របសម្រួល

### អ្នកសម្របសម្រួល



**លោកបណ្ឌិត អ៊ុំ សុធា**
នាយកប្រតិបត្តិ
នៃមជ្ឈមណ្ឌលគោលនយោបាយយុទ្ធសាស្ត្រ និងនវានុវត្តន៍



**លោក ឈាវ ណារ៉ាត**
សមាជិកក្រុមប្រឹក្សាភិបាល នៃសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា

### វាគ្មិនកិត្តិយស



**លោក ឡេង សុខឡុង**
ទីប្រឹក្សា
នៃនិយតករសន្តិសុខសង្គមកម្ពុជា



**កញ្ញា បូរ៉ា ស៊ុនហ្សូលីណែត**
អ្នកស្រាវជ្រាវ
នៃមជ្ឈមណ្ឌលគោលនយោបាយយុទ្ធសាស្ត្រ និងនវានុវត្តន៍

# ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងវិស័យឯកជនក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា



រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមអនុវត្តដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ (D&D) ជាងមួយទសវត្សរ៍មកហើយ ក្នុងគោលបំណងបង្កើនការឆ្លើយតប ប្រសិទ្ធភាព និងគណនេយ្យភាពនៃការផ្តល់សេវា។ ក្រោមក្របខណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការទទួលខុសត្រូវលើការផ្តល់សេវាត្រូវបានផ្ទេរជូនរដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) ដូចជា ឃុំ/សង្កាត់ ស្រុក ក្រុង ខណ្ឌ និងរាជធានីខេត្តជាដើម។ ការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ គឺជាគន្លឹះ ដើម្បីសម្រេចជោគជ័យនៃរបៀបវារៈកំណែទម្រង់នេះ។ ក្នុងឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តលើកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ដំណាក់កាលទី២ ដែលគូសបញ្ជាក់ពីតួនាទីនៃការរៀបចំផែនការប្រកបដោយប្រសិទ្ធភាព របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការធ្វើវិមជ្ឈការសារពើពន្ធ។

ការផ្គត់ផ្គង់ទឹកស្អាត រួមទាំងការផ្គត់ផ្គង់ទឹកតាមបំពង់ គឺជាសេវាមួយ ក្នុងចំណោមសេវាចាំបាច់សំខាន់ៗដែលត្រូវធ្វើការកែលម្អ តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ក្នុងការផ្តល់សេវាទាំងនេះ រដ្ឋាភិបាលថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ អាច ១) ផ្តល់សេវាដោយផ្ទាល់ ឬ ២) បំពេញតួនាទីជានិយ័តករ និងជាអ្នកសម្របសម្រួលជូនប្រតិបត្តិករឯកជន។ នៅកម្ពុជាមានការផ្តោតការយកចិត្តទុកដាក់ជាច្រើនលើតួនាទីទី១ ប៉ុន្តែមិនសូវមានការយកចិត្តទុកដាក់លើតួនាទីទី២ នោះឡើយ។ ការរួមតូចនៃលំហសារពើពន្ធរបស់រដ្ឋាភិបាល ដែលកំពុងមានកម្រិតរួច

ទៅហើយ ក្រោយវិបត្តិកូវីដ-១៩ បង្ហាញថា គួរមានការផ្តល់ការយកចិត្តទុកដាក់បន្ថែមទៀតដល់តួនាទីទី២ នៅឆ្នាំបន្តបន្ទាប់ខាងមុខនេះ។ ទិន្នន័យដែលមានបង្ហាញថា កន្លងមក មានការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុជាច្រើនពីតួអង្គមិនមែនរដ្ឋ និងរឹតតែច្រើនទៅទៀតពីការវិនិយោគឯកជនក្នុងការផ្តល់សេវា និងការវិនិយោគនានា ជាពិសេសលើការផ្គត់ផ្គង់ទឹកដល់ប្រជាពលរដ្ឋទាំងនៅជនបទ ទាំងនៅប្រជុំជន។

ទោះជាយ៉ាងនេះក្តី ភាពជាដៃគូបច្ចុប្បន្នរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា និងប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជន នៅមិនទាន់ត្រូវបានអនុវត្តឱ្យបានល្អប្រសើរនៅឡើយ។ បើតាមគោលនយោបាយដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះ ថ្នាក់ស្រុក ក្រុង ខណ្ឌ (DMK) គឺជាកម្រិតរដ្ឋបាលដែលត្រូវទទួលខុសត្រូវជាចម្បងលើការផ្តល់សេវា រាប់បញ្ចូលទាំងការផ្គត់ផ្គង់ទឹកស្អាតផងដែរ។ ទោះជាយ៉ាងនេះក្តី នៅក្នុងស្ថានភាពជាក់ស្តែង ក្រោយពេលអនុវត្តកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការជាងមួយទសវត្សរ៍រួចមក ថ្នាក់ស្រុក ក្រុង ខណ្ឌ បានទទួលធនធានតិចតួចជាងគេ បើធៀបនឹងរាជធានីខេត្ត និងឃុំ/សង្កាត់។ លើសពីនេះ ខណៈពេលដែលគោលនយោបាយរបស់រដ្ឋាភិបាលទទួលស្គាល់ពីសារៈសំខាន់នៃការសហការជាមួយវិស័យឯកជន ក្នុងការកែលម្អសេវានៅតាមមូលដ្ឋាន កន្លងមកនៅមិនទាន់មានការកំណត់ពីតួនាទីរបស់រដ្ឋបាលស្រុក ក្រុង ខណ្ឌ ឱ្យបានច្បាស់លាស់នៅឡើយ ហើយក៏មិនទាន់មានការដាក់ឱ្យអនុវត្តយន្តការដាក់លាក់នោះដែរ។ ភាពខ្វះចន្លោះបែបនេះ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់ការបំពេញតួនាទីរបស់រដ្ឋបាលស្រុក ក្រុង ខណ្ឌ ប៉ុណ្ណោះទេ ថែមទាំងបង្កផលវិបាកដល់ការកំណត់គោលដៅ និងការធានាគណនេយ្យភាពជុំវិញការវិនិយោគលើការផ្គត់ផ្គង់ទឹកតាមបំពង់ និងការផ្តល់សេវាផងដែរ។

កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយសស្តីពី "ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយវិស័យឯកជន៖ ក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា" ត្រូវបានធ្វើឡើង ដើម្បីពិភាក្សាពីស្ថានភាពបច្ចុប្បន្ន និងការរៀបចំដែលក្នុងនោះរដ្ឋបាលមូលដ្ឋាន ជាពិសេសរដ្ឋបាលថ្នាក់ស្រុក/ក្រុង អាចសហការយ៉ាងជិតស្និទ្ធជាមួយនឹងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដោយមានការគាំទ្រពីក្រសួងនៅថ្នាក់ជាតិ ដើម្បីឱ្យមានការផ្តល់សេវាផ្គត់ផ្គង់ទឹកតាមបំពង់កាន់តែប្រសើរទាំងតំបន់ប្រជុំជន និងតំបន់ជនបទ។

## សង្ខេបលទ្ធផលនៃកិច្ចពិភាក្សា

តាមរយៈដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ មុខងារផ្គត់ផ្គង់ទឹកស្អាត ត្រូវបានផ្ទេរទៅឱ្យការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍។ ការិយាល័យនេះ ទទួលបន្ទុកអនុវត្តមុខងារដែលផ្ទេរពីក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ សម្រាប់ក្រសួងអភិវឌ្ឍនជនបទ មុខងារផ្ទេរ រួមមាន 'សាងសង់ ជួសជុល ថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ។' ដោយឡែកសម្រាប់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍វិញ មុខងារដែលត្រូវបានផ្ទេររួមមាន 'ការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកតាមបំពង់ (ក្រោយពេលបានទទួលអាជ្ញាប័ណ្ណពីក្រសួងនេះរួច)'។

គេជឿថា ការផ្ទេរមុខងារគ្រប់គ្រងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ទៅឱ្យរដ្ឋបាលស្រុក/ក្រុង នឹងជួយបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅកម្រិតរដ្ឋបាលស្រុក/ក្រុង។ប៉ុន្តែការអនុវត្តមុខងារជាក់ស្តែងរបស់រដ្ឋបាលមូលដ្ឋានក្នុងការបង្កើនការទទួលបានទឹកស្អាត និងមានសុវត្ថិភាពតាមបំពង់ នៅមានកម្រិតតិចតួចនៅឡើយដោយសារតែ៖១)អំណាចដែលផ្ទេរឱ្យរដ្ឋបាលមូលដ្ឋានពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់មានលក្ខណៈតូចចង្អៀតពេក ដែលមិនអាចឱ្យរដ្ឋបាលមូលដ្ឋានបំពេញភារកិច្ចនេះប្រកបដោយប្រសិទ្ធភាព ២) រដ្ឋបាលមូលដ្ឋានពុំបានទទួលការបំពាក់មធ្យោបាយដែលចាំបាច់ សម្រាប់អនុវត្តមុខងារទាំងនេះ និង ៣) រដ្ឋបាលមូលដ្ឋានខ្វះធនធានសម្រាប់អនុវត្តមុខងារថ្មីនេះប្រកបដោយជោគជ័យ។

ដោយឡែកប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជន បានរួមចំណែកយ៉ាងច្រើនដល់វិស័យផ្គត់ផ្គង់ទឹកស្អាត។ ទោះជាយ៉ាងនេះក្តី ប្រតិបត្តិករភាគច្រើនទទួលបន្ទុកទាំងស្រុង លើការផ្តល់ហិរញ្ញប្បទានការរចនា ការសាងសង់ និងដំណើរការនៃប្រព័ន្ធផ្គត់ផ្គង់ទឹក និងជួបការលំបាកជាច្រើន ដូចជា ការខូចប្រព័ន្ធផ្គត់ផ្គង់ទឹកតាមបំពង់ដោយពុំបានទទួលសំណង ទុនវិនិយោគមិនគ្រប់គ្រាន់ ការកំណត់តួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលមូលដ្ឋានមិនមានភាពច្បាស់លាស់ ប្រភពទឹកពុំមាននិរន្តរភាព លក្ខខណ្ឌភូមិសាស្ត្រនិងប្រជាសាស្ត្រមិនអំណោយផល ដង់ស៊ីតេប្រជាជនទាប ហើយប្រជាពលរដ្ឋនៅតាមខ្នងផ្ទះ មិនសូវចង់ប្រើប្រាស់ការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់។

ការស្រាវជ្រាវនេះបានប្រើប្រាស់វិធីសាស្ត្រអង្កេត ដើម្បីប្រមូលទិន្នន័យពីអ្នកប្រើប្រាស់ទឹក។ លទ្ធផលនៃការអង្កេតដែលធ្វើឡើងជាមួយប្រជាពលរដ្ឋចំនួន ២០៦គ្រួសារ បានបង្ហាញថាគ្រួសារប្រមាណ ១៧% មិនបានភ្ជាប់ការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ចូលមកផ្ទះរបស់ពួកគេឡើយ ហើយពួកគេភាគច្រើនប្រើប្រាស់ទឹកពីអណ្តូង។ សម្រាប់គ្រួសារដែលអាចទទួលបានការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ជិត ៥០% បានត្អូញត្អែរទៅកាន់ប្រតិបត្តិការផ្គត់ផ្គង់ទឹកឯកជនពាក់ព័ន្ធនឹងគុណភាពទឹក និងបរិមាណទឹកមិនបិតបេរ ថ្លៃទឹកខ្ពស់ ការឆ្លើយតបទៅនឹងសេវាអតិថិជន និងការលំបាកក្នុងការទាក់ទងទៅកាន់ក្រុមហ៊ុនទាំងនោះ។ ពួកគេលើកឡើងថា ជារឿយៗពួកគេពុំបានទទួលការឆ្លើយតបជាទីពេញចិត្ត ហើយពេលខ្លះពុំបានទទួលការឆ្លើយតបតែម្តង។

ដើម្បីជានាភាពជាដៃគូប្រកបដោយប្រសិទ្ធភាព រវាងរដ្ឋបាលមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជន រដ្ឋបាលនៅកម្រិតនានា គួរយកអនុសាសន៍ខាងក្រោមសម្រាប់ធ្វើការពិចារណា៖

- ថ្នាក់ស្រុក និងឃុំ៖
    - បង្កើនថវិកា និងផ្តល់អាទិភាពដល់សកម្មភាពសំខាន់ៗ
    - ពង្រឹងទំនាក់ទំនងរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជន និងអាជ្ញាធរ តាមរយៈកិច្ចប្រជុំ ប្រចាំខែ
    - រៀបចំវេទិកាសាធារណៈ និងចុះពិនិត្យតាមដានឱ្យបានទៀងទៀត
    - រៀបចំបញ្ជីអ្នកជំនាញផ្នែកទឹកស្អាត និងអនាម័យនៅក្នុងមូលដ្ឋាន និងកសាងសមត្ថភាពមន្ត្រីនៅមូលដ្ឋាន
    - បញ្ចូលប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជន ទៅក្នុងការធ្វើផែនការអភិវឌ្ឍស្រុក/ឃុំ

- ជំរុញឱ្យមានការប្រើប្រាស់ទឹកស្អាតនៅតាមសហគមន៍ និងការពារប្រភពទឹក

- ប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជនៈ
  - ឆ្លើយតបចំពោះបញ្ហា/ក្ដីបារម្ភនានាដែលលើកឡើងដោយអ្នកប្រើប្រាស់ទឹក
  - បង្កើនសមត្ថភាពប្រតិបត្តិការ និងគ្រប់គ្រងរបស់បុគ្គលិកក្នុងការគោរពតាមបទបញ្ជានានា
  - ផ្តល់ទិន្នន័យជូនអាជ្ញាធរឃុំ/ស្រុក ដូចជា ផែនទីបណ្តាញបំពង់ទឹកជាដើម
  - សហការជាមួយអាជ្ញាធរឃុំ និងក្រុមហ៊ុនសង់ផ្លូវក្នុងមូលដ្ឋាន ដើម្បីកាត់បន្ថយការខូចខាតបណ្តាញបំពង់ទឹកឱ្យនៅតិចជាអប្បរមា
- អាជ្ញាធរខេត្តៈ
  - លើកទឹកចិត្តឱ្យមានការវិនិយោគលើការផ្គត់ផ្គង់ទឹក
  - ប្រមូលកៀរគរធនធានសម្រាប់វិនិយោគក្នុងការផ្គត់ផ្គង់ទឹក
  - ជួយសម្រួលដល់វិនិយោគិនក្នុងការអនុវត្តគម្រោងនានារបស់ពួកគេ
- ក្រសួងៈ
  - ពិនិត្យជាប្រចាំ និងកែលម្អនីតិវិធីផ្តល់អាជ្ញាប័ណ្ណ
  - ពន្លឿនការរៀបចំ និងការចេញឯកសារគតិយុត្ត ផ្តល់ការណែនាំលម្អិត គោលការណ៍ណែនាំបច្ចេកទេស និងសៀវភៅណែនាំប្រតិបត្តិការលើបញ្ហាដែលពាក់ព័ន្ធ
  - ផ្សព្វផ្សាយព័ត៌មាន និងបែងចែកធនធានឱ្យបានទូលំទូលាយ ដល់រដ្ឋបាលមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
- ស្ថាប័នពាក់ព័ន្ធទាំងអស់ៈ
  - ធ្វើការងារឱ្យបានជិតស្និទ្ធរួមគ្នា ដើម្បីលុបបំបាត់ប្រតិបត្តិការស្ទួន ក៏ដូចជា ត្រូវបែងចែកតួនាទី និងភារកិច្ចឱ្យបានច្បាស់លាស់
  - បង្កើតវេទិកាទំនាក់ទំនងឱ្យមានប្រសិទ្ធភាព ដែលក្នុងនោះទីភ្នាក់ងារពាក់ព័ន្ធ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជន អាចទំនាក់ទំនង សម្របសម្រួល និងចែករំលែកព័ត៌មានជាមួយគ្នាបានកាន់តែប្រសើរ។

## វាគ្មិន និងអ្នកសម្របសម្រួល

**អ្នកសម្របសម្រួល**



លោក ម៉ក់ សុខា
អ្នកគ្រប់គ្រងកម្មវិធី
នៃ WaterAid Cambodia



លោកស្រី គង់ ប៊ុណ្ណា
អនុប្រធាន នាយកដ្ឋានវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)

**វាគ្មិនកិត្តិយស**



លោក លឹម មិញ
នាយកប្រតិបត្តិ
នៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា



លោកបណ្ឌិត សៅ ដារី
នាយកប្រតិបត្តិ
នៃអង្គការប្រើប្រាស់ទឹកប្រកបដោយចីរភាព



អ្នកនាង ទីន ម៉ូឡា
ប្រធានផ្នែកហេដ្ឋារចនាសម្ព័ន្ធ
នៃកិច្ចសហប្រតិបត្តិការកម្ពុជា-អូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចធន់

## ការស្ម័គ្រចិត្តរបស់យុវជន អក្ខរកម្មផ្នែកឌីជីថល និងការអភិវឌ្ឍសហគមន៍៖ ករណីសិក្សាកម្មវិធីអ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំនៅកម្ពុជា និងផែនទីបង្ហាញផ្លូវសម្រាប់ក្រុមយុវវ័យ និងយុវជន



កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបិទគ្រឹះស្ថានអប់រំទាំងអស់ ទាំងសាធារណៈ និងឯកជន ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។ ការបិទទ្វារសាលារៀន នាំឱ្យមានការរំខានដល់ការរៀនសូត្ររបស់សិស្សនៅក្នុងសាលារដ្ឋទាំង ១៣.៤៨២ កន្លែង ក្នុងប្រទេសកម្ពុជា ចាប់ពីកម្រិតមត្តេយ្យសិក្សា រហូតដល់មធ្យមសិក្សាទុតិយភូមិ រួមទាំងសាលាមត្តេយ្យសហគមន៍ មជ្ឈមណ្ឌលនិងកម្មវិធីអប់រំក្រៅប្រព័ន្ធ និងគ្រឹះស្ថានអប់រំគ្រូចំនួន ៣.០៦៤កន្លែង ផងដែរ។ជាលទ្ធផលមានសិស្សប្រមាណ៣,២លាននាក់ រងផលប៉ះពាល់។ ជាការឆ្លើយតប ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយដៃគូអភិវឌ្ឍ និងតួអង្គពាក់ព័ន្ធនានាបានខិតខំប្រឹងប្រែងរៀបចំឱ្យមានការបន្តការសិក្សាពីចម្ងាយសម្រាប់សិស្សានុសិស្សគ្រប់រូបនៅកម្ពុជា។[16]

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និងជាពិសេសក្នុងអំឡុងពេលដែលមានការផ្ទុះជំងឺកូវីដ-១៩ នៅកម្ពុជា គេដឹងថាកុមារ និងយុវជនប្រើប្រាស់អ៊ីនធឺណិត និងថ្នាក់បច្ចេកវិទ្យាតាមប្រព័ន្ធអនឡាញកាន់តែច្រើនជាងមុន ហើយក៏មានការលើកទឹកចិត្តឱ្យពួកគេប្រើប្រាស់បច្ចេកវិទ្យាទាំងនេះ ដើម្បីទទួលបានការអប់រំតាមប្រព័ន្ធឌីជីថល។ បើទោះជាមានបំណងល្អបែបនេះក៏ដោយ ដោយសារពុំមានយន្តការបង្កើនការយល់ដឹង គាំទ្រ ផ្តល់ចំណេះដឹង និងការពារឱ្យបានសមស្របបច្ចុប្បន្នយុវជន និងកុមារជាច្រើននាក់ បានក្លាយជាជនរងគ្រោះនៃការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ ហើយក្នុងពេលជាមួយគ្នា ការចូលទៅមើលគេហទំព័រមិនសមស្រប ធ្វើឱ្យពួកគេ

[16] ការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំ ក្នុងអំឡុងពេលដែលមានការរីករាលដាលនៃជំងឺកូវីដ ១៩ នៅកម្ពុជា របស់ក្រសួងអប់រំ យុវជន និងកីឡា ខែមីនា ឆ្នាំ ២០២១។

កាន់តែងាយរងគ្រោះនិងប្រឈមនឹងហានិភ័យ។ប៉ុន្តែ កម្មវិធីអ្នកស្ម័គ្រចិត្តនៅក្នុងមូលដ្ឋានកំពុងជួយឱ្យយុវជនអាចទទួលបានជំនាញអនឡាញបានកាន់តែប្រសើរ ក៏ដូចជាផ្សព្វផ្សាយជំនាញទាំងនេះដល់សហគមន៍តាមរយៈគម្រោងផ្តល់សេវា។

កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយសស្តីពី "ការស្ម័គ្រចិត្តរបស់យុវជន អក្ខរកម្ម ផ្នែកឌីជីថល និងការអភិវឌ្ឍសហគមន៍" ធ្វើឡើង ដើម្បីពិភាក្សា និងស្វែងយល់ថាតើកម្មវិធីយុវជនស្ម័គ្រចិត្ត និងអក្ខរកម្មឌីជីថល អាចជួយកសាងជំនាញទន់ដល់យុវជន និងជួយពួកគេឱ្យអាចរួមចំណែកដល់ការអភិវឌ្ឍសហគមន៍ និងឆ្លើយតបចំពោះបញ្ហានានាបានយ៉ាងដូចម្តេចខ្លះ ដូចជា បង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាដើម។ នៅក្នុងកម្មវិធីនេះ ក៏មានការបង្ហាញពីកម្មវិធីយុវជនស្ម័គ្រចិត្តថ្នាក់ជាតិរបស់រដ្ឋាភិបាល ដែលមានឈ្មោះថាកម្មវិធីស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ (VMC)។

## សង្ខេបលទ្ធផលនៃកិច្ចពិភាក្សា

កម្មវិធីស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ(VMC) និងក្រុមយុវវ័យ និងយុវជន (AYRG) ត្រូវបានអនុវត្ត ដើម្បីផ្តល់ឱកាសក្មេងជំទង់ និងយុវជនអាចចូលរួមរៀនសូត្រ និងផ្តួចផ្តើមសកម្មភាពបង្កើនជំនាញ និងអភិវឌ្ឍសហគមន៍។ កម្មវិធី VMC ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៩ ដែលមានការឧបត្ថម្ភពីកម្មវិធីអ្នកស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិ (UNV) ដើម្បីអនុវត្តសកម្មភាពក្នុងខេត្តចំនួន ១២ នៅទូទាំងប្រទេសកម្ពុជា ហើយកម្មវិធី AYRG ត្រូវបានបង្កើតឡើងកាលពីឆ្នាំ២០១៥ និងត្រូវបានផ្ទេរទៅឱ្យកាកបាទក្រហមកម្ពុជាកាលពីឆ្នាំ២០១៧ ដើម្បីអនុវត្តក្នុងខេត្តចំនួន ១០។

កម្មវិធីនេះផ្តល់ការបណ្តុះបណ្តាលអំពីប្រធានបទជាច្រើន ដូចជា ការសរសេរសំណើ ការប្រាស្រ័យទាក់ទង ការសរសេររបាយការណ៍ ការគ្រប់គ្រងថវិកា ជំនាញឌីជីថល និងសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ លើសពីនេះ កម្មវិធីនេះ ក៏ផ្តល់ថវិកាឧបត្ថម្ភខ្នាតតូចមួយចំនួនដល់អ្នកស្ម័គ្រចិត្ត ដែលកំពុងធ្វើសកម្មភាពក្នុងវិស័យចំនួន៨ ដើម្បីឆ្លើយតបចំពោះបញ្ហាសហគមន៍ ដូចជា ៖ អប់រំ បរិស្ថាន កសិកម្ម ទេសចរណ៍ សុខភាព រដ្ឋបាលសាធារណៈ សហគ្រិនភាព និងឧស្សាហកម្ម៤.0 ជាដើម។ ទាំងកម្មវិធី AYRG និងកម្មវិធី VMC សុទ្ធតែបំពេញតួនាទីសំខាន់ក្នុងការឆ្លើយតបចំពោះបញ្ហាប្រែប្រួលអាកាសធាតុ តាមរយៈការកៀរគរសិស្ស និងសហគមន៍ឱ្យដាំដើមឈើ ដើម្បីឱ្យបរិស្ថានមានពណ៌បៃតង ការគ្រប់គ្រងសំណល់ និងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក។ លើសពីនេះ កម្មវិធី AYRG ក៏បានរៀបចំកិច្ចពិគ្រោះយោបល់ជាមួយសមាជិកនៅថ្នាក់ក្រោមជាតិ ដើម្បីប្រមូលធាតុចូល និងអនុសាសន៍ស្តីពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ សម្រាប់រៀបចំជាសេចក្តីថ្លែងការណ៍រួមគ្នាមួយ ដាក់ជូនទៅក្រសួងពាក់ព័ន្ធ ក្នុងការឆ្លើយតប និងផ្តល់ការគាំទ្រ។

ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ សកម្មភាពមួយចំនួនត្រូវបានបង្ខំឱ្យធ្វើតាមប្រព័ន្ធអនឡាញវិញ។ នេះជាការលំបាកដោយសារតែអ្នកស្ម័គ្រចិត្ត និងបុគ្គលិកនៃកម្មវិធី VMC

និង AYRG មានជំនាញតិចតួចប៉ុណ្ណោះពាក់ព័ន្ធនឹងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ដូច្នេះ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមនេះ ជនបង្គោលនៃកម្មវិធី VMC បានសហការជាមួយអង្គការសង្គមស៊ីវិល និងទីភ្នាក់ងារសហប្រជាជាតិ ដើម្បីផ្តល់ការកសាងសមត្ថភាពដល់ VMC ផ្តោតលើប្រធានបទបច្ចេកវិទ្យាឌីជីថល ដូចជា របៀបប្រើប្រាស់កម្មវិធី Excel, Microsoft Word, Zoom, Google Meets, Microsoft Teams។ល។ ជាលទ្ធផល អ្នកស្ម័គ្រចិត្តទាំងនេះបានប្រើប្រាស់ជំនាញឌីជីថល ដើម្បីបន្តអនុវត្តគម្រោង តាមរយៈការជួបប្រជុំ ទំនាក់ទំនង និងអប់រំផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ។

ជាមួយនឹងបណ្តាញទំនាក់ទំនងសង្គម បច្ចុប្បន្ន អក្ខរកម្មឌីជីថលមានបញ្ចូលនូវជំនាញជាច្រើន ចាប់ពីការអាប់ឡូតមាតិកាក្នុង YouTube រហូតដល់ការចែករំលែកតាមប្រព័ន្ធហ្វេសប៊ុកជាដើម។ អ្នកស្ម័គ្រចិត្ត VMC ក៏បាននាំបច្ចេកវិទ្យាទាំងនេះ ទៅឱ្យសិស្សប្រើប្រាស់ផងដែរ និងបានលើកទឹកចិត្តឱ្យពួកគេប្រើប្រាស់ជំនាញឌីជីថល ដូចជា ការរៀបចំឯកសារ (Word, Excel, PowerPoint) និងការប្រើប្រាស់កម្មវិធី Google Meets និង Zoom ជាដើម។ ប៉ុន្តែ មានចំណុចមួយចំនួនដែលចាំបាច់ត្រូវធ្វើការកែលម្អបន្ថែមទៀត ដូចជា ផ្តល់ការបណ្តុះបណ្តាលបន្ថែមអំពីការរៀបចំយុទ្ធនាការតាមបណ្តាញទំនាក់ទំនងសង្គម ការកែវីដេអូ កម្មវិធី Google Earth ការថតវីដេអូ ការធ្វើការស្រាវជ្រាវ និងដំណោះស្រាយបច្ចេកវិទ្យាជាដើម។

អនុសាសន៍ខាងក្រោមនេះត្រូវបានលើកឡើង ដើម្បីឱ្យអ្នកស្ម័គ្រចិត្តនៃកម្មវិធី VMC និង AYRG អាចកសាងជំនាញទន់សម្រាប់យុវជន និងផ្តល់លទ្ធភាពឱ្យពួកគេអាចរួមចំណែកដល់ការអភិវឌ្ឍសហគមន៍៖

- រៀបចំកម្មវិធីសិក្សាដែលមានលក្ខណៈស្តង់ដារ និងបំប្លែងកម្មវិធីសិក្សាទាំងនេះ ជាវគ្គសិក្សាតាមថ្នាល បច្ចេកវិទ្យាឌីជីថល។
- រៀបចំការបណ្តុះបណ្តាល/សិក្ខាសាលាបន្ថែមទៀត ដើម្បីឱ្យអ្នកស្ម័គ្រចិត្តទទួលបានជំនាញគ្រប់គ្រាន់សម្រាប់ធ្វើការងារ និងអភិវឌ្ឍសហគមន៍ឱ្យកាន់តែមានប្រសិទ្ធភាព។
- ផ្តល់ការគាំទ្របច្ចេកទេស និងបរិក្ខារឌីជីថល ដើម្បីឱ្យអ្នកស្ម័គ្រចិត្តអាចចូលរួមក្នុងវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ និងអនុវត្តគម្រោងនានា។
- ការបង្ហាញ និងអនុវត្តបច្ចេកវិទ្យាជាមួយយុវជនទូទៅ និងយុវជននៅតំបន់ជនបទ មានសារៈសំខាន់យ៉ាងខ្លាំង ប៉ុន្តែកម្មវិធី គួរពិចារណាផ្គត់ផ្គង់ជាកុំព្យូទ័រ និងឧបករណ៍ផ្សេងទៀត ដើម្បីជួយដល់យុវជនទាំងនោះ។
- ពង្រឹងដំណើរការជ្រើសរើសអ្នកស្ម័គ្រចិត្តនៅថ្នាក់ខេត្ត ដើម្បីលើកកម្ពស់បរិយាបន្នតាមរយៈការលើកទឹកចិត្តឱ្យយុវជនមកពីតាមក្រុមផ្សេងៗបានចូលរួមដូចជា យុវជនមានពិការភាព ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) យុវជនជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះជាដើម។ល។
- រៀបចំ និងកំណត់ស្តង់ដារអំពីភារកិច្ចថែទាំយកចិត្តទុកដាក់ សម្រាប់អ្នកស្ម័គ្រចិត្ត ផ្អែកតាមឯកសារស្តង់ដារសកលស្តីពីការងារស្ម័គ្រចិត្ត។

# វាគ្មិន និងអ្នកសម្របសម្រួល

**អ្នកសម្របសម្រួល**



កញ្ញា ហួ បុផ្ផា

មន្ត្រីគម្រោង
នៃអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា

**វាគ្មិនកិត្តិយស**



លោក អ៊ុយ គា

អនុប្រធាននាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល
នៃក្រសួងអប់រំ យុវជន និងកីឡា



លោក យ៉ាន ឡាយ

នាយកប្រតិបត្តិ
នៃអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា



កញ្ញា កៅ ម៉េងហ័ង

អ្នកស្ម័គ្រចិត្ត
នៃកម្មវិធីស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ
(កំពង់ចាម)



លោក ពន់ គិរីក្រៃនេត្រ

អ្នកស្ម័គ្រចិត្ត
នៃកម្មវិធីស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ
(មណ្ឌលគីរី)



"កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា" របស់អង្គការមូលនិធិអាស៊ី សហការជាមួយនឹងដៃគូស្រាវជ្រាវរបស់ខ្លួន បានរៀបចំកម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹង ផ្តោតលើប្រធានបទ "ការលើកកម្ពស់វិស័យសេវាសាធារណៈ សម្រាប់ក្រុមងាយរងគ្រោះនៅកម្ពុជា" កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ នៅខេត្តសៀមរាប។ ផ្អែកតាមលទ្ធផលដែលទទួលបានពីការសិក្សា ដែលធ្វើឡើងកាលពីពេលថ្មីៗនេះ ដោយដៃគូនៃកម្មវិធីពន្លកចំណេះ និង ចំណេះដឹងរបស់តួអង្គពាក់ព័ន្ធសំខាន់ៗ ក្នុងវិស័យគោលនយោបាយ កម្មវិធីនេះមានការចូលរួមពីអ្នកចូលរួមជាង ១២០ នាក់ ដូចជា តំណាងរដ្ឋាភិបាល អ្នកស្រាវជ្រាវ សង្គមស៊ីវិល អ្នកធ្វើគោលនយោបាយ អ្នកជំនាញខាងគោលនយោបាយ តំណាងគ្រឹះស្ថានអប់រំ និងអ្នកការទូត ដើម្បីបង្ហាញ និងពិភាក្សាលទ្ធផលរកឃើញនៃការស្រាវជ្រាវ និងករណីសិក្សាអំពីប្រធានបទជាច្រើន។ ប្រធានបទទាំងនេះ រួមមានទេសចរណ៍ ការធ្វើចំណាកស្រុក ការអប់រំជនមានពិការភាព របបសោធនសម្រាប់វិស័យឯកជន ការផ្គត់ផ្គង់ទឹកស្អាត អក្ខរកម្មឌីជីថល ការអភិវឌ្ឍសហគមន៍ និងប្រធានបទដទៃទៀត ដែលសុទ្ធតែរួមចំណែកដល់ការលើកកម្ពស់វិស័យសេវាសាធារណៈសម្រាប់ក្រុមងាយរងគ្រោះនៃកម្ពុជា។

កម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងនេះ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយ ក្នុងចំណោមព្រឹត្តិការណ៍សំខាន់ៗនានា ដែលរៀបចំឡើង ដោយកម្មវិធីពន្លកចំណេះ ដើម្បីគាំទ្រដល់អង្គការក្នុងស្រុក ធ្វើការស្រាវជ្រាវ ប្រមូលទិន្នន័យទាន់ពេលវេលា ដើម្បីរួមចំណែកធ្វើឱ្យវិស័យសេវាសាធារណៈកាន់តែមានភាពប្រសើរសម្រាប់ក្រុមងាយរងគ្រោះនៅកម្ពុជា។

**ខាងក្រោមនេះ គឺជាសារគន្លឹះដែលទាញចេញពីកិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយសនីមួយៗ៖**

១. ការពិភាក្សាជាមួយវាគ្មិនកិត្តិយស ក្រោមប្រធានបទ "ការលើកកម្ពស់ការផ្តល់សេវាសាធារណៈដើម្បីជួយគាំទ្រដល់ក្រុមងាយរងគ្រោះនៅថ្នាក់ក្រោមជាតិ"៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍ គួររៀបចំឡើងតាមបែបចូលរួម ដោយត្រូវផ្តល់អាទិភាពដល់វិធីសាស្ត្រជំរុញការចូលរួមពីប្រជាពលរដ្ឋឱ្យបានសកម្ម និងប្រកបដោយអត្ថន័យក្នុងដំណើរការទាំងមូល ដើម្បីធានាបាននូវបរិយាបន្ន និងភាពឆ្លើយតបចំពោះយេនឌ័រ។ គួរមានការអនុវត្តយន្តការប្រមូលព័ត៌មានត្រឡប់ ដែលមានលក្ខណៈបរិយាបន្ន និងមានការរក្សាការសម្ងាត់ ដើម្បីធានាឱ្យមានការឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។ លើសពីនេះ គួរមានការប្រមូល ផ្សព្វផ្សាយ និងប្រើប្រាស់ទិន្នន័យ សម្រាប់ការរៀបចំ និងអនុវត្តគោលនយោបាយ។ ចំណុចសំខាន់ផងដែរនោះ គឺត្រូវធានាឱ្យមានការបែងចែកធនធានឱ្យបានច្រើនបន្ថែមទៀត ដើម្បីផ្តល់សេវាដល់ក្រុមប្រជាជនដែលងាយរងគ្រោះ។

២. ការពិភាក្សាជាមួយវាគ្មិនកិត្តិយស ក្រោមប្រធានបទ "ភាពធន់ និងការស្តារឡើងវិញរបស់បុគ្គលិកបម្រើការតាមសណ្ឋាគារនៅកម្ពុជា"៖ ការរីករាលដាលនៃជំងឺកូវីដ-១៩ បង្កផលប៉ះពាល់

យ៉ាងធ្ងន់ធ្ងរមកលើវិស័យទេសចរណ៍របស់កម្ពុជា ដូចជា តាមរយៈការរឹតត្បិតលើការធ្វើដំណើរ ការបិទផ្ទះសំណាក់និងសណ្ឋាគារ និងការបាត់បង់ការងារ។ យុទ្ធសាស្ត្រនាពេលអនាគត គួរផ្តោតលើការគាំទ្រឱ្យសហគ្រាសនានា ធ្វើពិពិធកម្មប្រភពចំណូលរបស់ខ្លួន ដើម្បីបម្រុងទល់នឹងវិបត្តិដែលអាចកើតមានឡើងដោយមិនបានរំពឹងទុកជាមុន។ លើសពីនេះ ក៏គួរផ្តោតការយកចិត្តទុកដាក់លើការបង្កើនជំនាញរបស់បុគ្គលិកក្នុងវិស័យទេសចរណ៍ និងជានាយ៉ាងណាឱ្យពួកគេអាចទទួលបានសេវាសាធារណៈ។

៣. ការពិភាក្សាជាមួយវាគ្មិនកិត្តិយស ក្រោមប្រធានបទ "ការស្វែងយល់អំពីសុខមាលភាពសង្គម បណ្តាញសង្គមនិងពលកម្មកុមារទាក់ទងការធ្វើចំណាកស្រុកពីប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ ក្នុងបរិបទកូវីដ-១៩"៖ ពលករចំណាកស្រុក ក៏រងផលប៉ះពាល់ច្រើនយ៉ាងដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ ដើម្បីគាំទ្រដល់ពលករចំណាកស្រុក ដែលកំពុងធ្វើការនៅប្រទេសថៃ គួរមានការពង្រីកប្រព័ន្ធគាំពារសង្គមសម្រាប់ពួកគេក្នុងលក្ខណៈជាប្រព័ន្ធ។ រដ្ឋាភិបាលក៏គួរពិចារណាគាំទ្រដល់បណ្តាញផ្លូវការ និងមិនផ្លូវការរបស់ពលករ ចំណាកស្រុក ក្នុងអំឡុងពេលដែលមានវិបត្តិ។ គួរមានការរៀបចំឱ្យកុមារដែលជាកូនៗរបស់ពលករចំណាកស្រុក អាចទទួលបានការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

៤. ការពិភាក្សាជាមួយវាគ្មិនកិត្តិយស ក្រោមប្រធានបទ "ផលប៉ះពាល់ដោយជំងឺកូវីដ-១៩លើការអប់រំរបស់ជនមានពិការភាពនៅកម្ពុជា"៖ ដើម្បីសម្រេចការអប់រំប្រកបដោយបរិយាបន្នគួរមានការរៀបចំវិធីសាស្ត្របង្រៀន និងកម្មវិធីសិក្សា ដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្សេងៗគ្នារបស់សិស្សមានពិការភាព ទន្ទឹមពេលនឹងមានការផ្តល់ការបណ្តុះបណ្តាលអំពីការអប់រំពិសេស។ លើសពីនេះ ការបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋអំពីជនមានពិការភាព មានសារៈសំខាន់ ដើម្បីជានាឱ្យមានគោរព ការយល់ដឹង និងការចូលរួមរបស់សិស្សមានពិការភាពនៅក្នុងសង្គម។

៥. ការពិភាក្សាជាមួយវាគ្មិនកិត្តិយស ក្រោមប្រធានបទ "គម្រោងប្រាក់សោធន៍និវត្តន៍សម្រាប់វិស័យឯកជននៅកម្ពុជា៖ ការត្រៀមខ្លួន និងផលប៉ះពាល់នៃសុខមាលសង្គម"៖ ខណៈពេលដែលនិយោជក និងនិយោជិតបានដឹង និងត្រៀមខ្លួនអនុវត្តរបបសោធនសម្រាប់វិស័យឯកជនជាការសំខាន់ណាស់ដែលគេត្រូវបន្តពង្រីកការគ្របដណ្តប់លើនិយោជិត ដែលបានបំពេញលក្ខណៈសម្បត្តិ និងត្រូវបន្តការរក្សាការជឿទុកចិត្ត និងប្រសិទ្ធភាពនៃការគ្រប់គ្រង ចាត់ចែងរបបនេះ។ ស្របគ្នានេះដែរ ការបង្កើនគុណភាព និងសមត្ថភាពគ្រប់គ្រងរបស់បេឡាជាតិសន្តិសុខសង្គម ក្នុងការគ្រប់គ្រងប្រាក់សោធនដែលបន្តកើនឡើងនាពេលអនាគតប្រកបដោយចីរភាព គឺជាកិច្ចការមួយដ៏សំខាន់។ រដ្ឋាភិបាល គួរសហការឱ្យបានជិតស្និទ្ធជាមួយនិយោជកដើម្បីសម្រាលបន្ទុកដែលកើតឡើងដោយសារការចូលរួមបង់ភាគទានទៅក្នុងរបបនេះ ដូចជាតាមរយៈការផ្តល់ការលើកទឹកចិត្តផ្នែកច្បាប់ និងការពង្រឹងបរិយាកាសធុរកិច្ចជាដើម។

៦. ការពិភាក្សាជាមួយវាគ្មិនកិត្តិយស ក្រោមប្រធានបទ "ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹង វិស័យឯកជនក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា"៖ ប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជនបំពេញតួនាទីយ៉ាងសំខាន់ក្នុងការពង្រីកការគ្របដណ្តប់នៃសេវាទឹកស្អាតទូទាំងប្រទេស។ អាជ្ញាធរមូលដ្ឋានបានកំណត់ពីបញ្ហាប្រឈមជាច្រើន ដូចជា ការធ្វើផែនការ ការរៀបចំថវិកាការគ្រប់គ្រងនិងការកសាងសមត្ថភាព រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព ដើម្បីអាចចូលរួមសហការជាមួយនឹងវិស័យឯកជន។ វិស័យឯកជនក៏បានលើកឡើងពីបញ្ហាប្រឈមសំខាន់ៗផ្សេងទៀត ដូចជា ការធ្វើឱ្យខូចប្រព័ន្ធផ្គត់ផ្គង់ទឹកបំពង់ មូលនិធិវិនិយោគពុំមានគ្រប់គ្រាន់ ស្ថានភាពភូមិសាស្ត្រនិងប្រជាសាស្ត្រពុំមានលក្ខណៈអំណោយផល និងប្រជាពលរដ្ឋមូលដ្ឋានមិនសូវចង់ប្រើប្រាស់ទឹកស្អាតតាមបំពង់។ ដើម្បីជានាភាពជាដៃគូប្រកបដោយប្រសិទ្ធភាព រវាងរដ្ឋបាលមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជន ស្ថាប័នពាក់ព័ន្ធនានាចាំបាច់ត្រូវសហការគ្នាឱ្យបានជិតស្និទ្ធ ដើម្បីកំណត់ពីតួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ក៏ដូចជា ជំរុញឱ្យមានទំនាក់ទំនង និងការសម្របសម្រួលជាមួយគ្នាឱ្យបានសកម្ម។

៧. ការពិភាក្សាជាមួយវាគ្មិនកិត្តិយស ក្រោមប្រធានបទ "ការស្ម័គ្រចិត្តរបស់យុវជន អក្ខរកម្មផ្នែកឌីជីថល និងការអភិវឌ្ឍសហគមន៍៖ ករណីសិក្សាកម្មវិធីអ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ (VMC) នៅកម្ពុជា និងផែនទីបង្ហាញផ្លូវសម្រាប់ក្រុមយុវវ័យ និងយុវជន (AYRG)"៖ ការងារស្ម័គ្រចិត្តរបស់យុវជនមានសារៈសំខាន់ ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍសហគមន៍ និងការអភិវឌ្ឍជំនាញរបស់អ្នកស្ម័គ្រចិត្តម្នាក់ៗ។ ដូច្នេះ គួរមានការពង្រឹងដំណើរការជ្រើសរើសអ្នកស្ម័គ្រចិត្តនៅតាមបណ្តាខេត្ត ដើម្បីលើកកម្ពស់បរិយាបន្ន តាមរយៈការលើកទឹកចិត្តឱ្យយុវជនមកពីក្រុមនានា បានចូលរួម ដូចជា យុវជនមានពិការភាព ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា យុវជនជាជនជាតិដើមភាគតិច និងយុវជនមកពីក្រុមដែលងាយរងគ្រោះជាដើម។ គួរមានការពង្រឹងជាវគ្គបណ្តុះបណ្តាល ដើម្បីជួយឱ្យយុវជនអាចទទួលបានជំនាញទន់ និងជាពិសេសជំនាញអក្ខរកម្មឌីជីថល។

# ឧបសម្ព័ន្ធទី ១

## របាយការណ៍វាយតម្លៃកម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹង

រាជរដ្ឋាភិបាលកម្ពុជាខិតខំលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដើម្បីធានាយ៉ាងណាឱ្យប្រជាពលរដ្ឋ រាប់បញ្ចូលទាំងក្រុមងាយរងគ្រោះ និងក្រុមដែលមានឱកាសតិចតួច អាចទទួលបានសេវាសាធារណៈប្រកបដោយសមភាព។[17] គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ មានសមិទ្ធផលជាច្រើនត្រូវបានសម្រេច។ ឧទាហរណ៍ មានកុមារជាង ៩៧% បានចូលរៀននៅកម្រិតបឋមសិក្សាកាលពីឆ្នាំ២០១៧[18] ប្រជាពលរដ្ឋកម្ពុជា ៨៦,៤% មានអគ្គិសនីប្រើប្រាស់នៅក្នុងឆ្នាំ២០២០[19]និងប្រជាពលរដ្ឋនៅជនបទ ៨០% មានទឹកស្អាត និងសេវាអនាម័យប្រើប្រាស់ក្នុងឆ្នាំ២០២២។[20]

ផ្អែកតាមគំនិតយោបល់ ដែលទទួលបានពីការសិក្សាស្រាវជ្រាវ ដែលធ្វើឡើងដោយដៃគូនៃកម្មវិធីពន្លកចំណេះ កាលពីពេលថ្មីៗនេះ ក៏ដូចជា ចំណេះដឹងរបស់តួអង្គសំខាន់ៗ ដែលធ្វើការងារពាក់ព័ន្ធនឹងវិស័យគោលនយោបាយ កម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងនៃកម្មវិធីពន្លកចំណេះ បំពេញតួនាទីជាវេទិកាសម្រាប់ឱ្យអ្នកស្រាវជ្រាវធ្វើការបង្ហាញពីរបកគំហើញរបស់ខ្លួន ពិភាក្សាផ្លាស់ប្តូរចំណេះដឹង និងកសាងបណ្តាញជាមួយអ្នកប្រើប្រាស់លទ្ធផលដែលបានពីការស្រាវជ្រាវនេះ តាមរយៈការវាយតម្លៃលើកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល និងផ្តល់ជាអនុសាសន៍ ដើម្បីឱ្យមានការផ្តល់សេវាសាធារណៈកាន់តែប្រសើរដល់ក្រុមងាយរងគ្រោះនៅកម្ពុជា។

កម្មវិធីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងនៃកម្មវិធីពន្លកចំណេះនេះមានវត្ថុបំណង៖

- បង្ហាញលទ្ធផលនៃការស្រាវជ្រាវ និងទិន្នន័យដែលឆ្លើយតបទៅនឹងតម្រូវការគោលនយោបាយដើម្បីលើកកម្ពស់សេវាសាធារណៈសម្រាប់ក្រុមងាយរងគ្រោះ។
- លើកកម្ពស់ការពិភាក្សាអំពីការស្រាវជ្រាវ និងផ្លាស់ប្តូរចំណេះដឹងរវាងអ្នកតាក់តែងគោលនយោបាយ និងអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បង្កើតបរិយាកាសអំណោយផលសម្រាប់តួអង្គក្នុងវិស័យស្រាវជ្រាវជួបពិភាក្សា និងពង្រីកបណ្តាញ ទំនាក់ទំនងដើម្បីកសាងសហគមន៍ស្រាវជ្រាវនៅកម្រិតថ្នាក់ខេត្ត។

ដើម្បីធ្វើឱ្យការរៀបចំកម្មវិធីបែបនេះនាពេលអនាគតកាន់តែមានភាពប្រសើរ និងដើម្បីប្រមូលមតិយោបល់អំពីប្រធានបទដែលគួរមានសម្រាប់កម្មវិធីនាពេលអនាគត ការស្ទាបស្ទង់មតិក្រោយកម្មវិធីនេះ ត្រូវបានធ្វើឡើង។ លទ្ធផលនៃការស្ទាបស្ទង់មតិ បង្ហាញថាអ្នកចូលរួមជាង ៨០% ដាក់ពិន្ទុថា 'ពេញចិត្ត' និង 'ពេញចិត្តខ្លាំង' ចំពោះការគ្រប់គ្រងកម្មវិធី និងការសម្របសម្រួលនានា ដូចជា ការរៀបចំកម្មវិធី ការបកប្រែភាសា គុណភាពសំឡេង ការរៀបចំបន្ទប់ និងទុកពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាជាដើម។ ប៉ុន្តែ មានចំណុចមួយចំនួនតូចដែលត្រូវធ្វើការ

---

[17] https://www.khmersme.gov.kh/wp-content/uploads/2022/09/Rectangular-Strategy-Phase-IV.pdf

[18] https://www.unicef.org/cambodia/education#:~:text=Cambodia%20has%20made%20terrific%20progress,in%20school%20year%202017%2F18.

[19] https://data.worldbank.org/indicator/EG.ELC.ACCS.ZS?locations=KH

[20] https://www.khmertimeskh.com/501123910/over-80-pct-of-cambodias-rural-population-have-access-to-clean-water-sanitation/

កែលម្អ ដូចជា បន្ទប់ខ្លះតូចពេលដែលមិនអាចដាក់អ្នកចូលរួមទាំងអស់ដែលចាប់អារម្មណ៍ចំពោះប្រធានបទ និងគួរទុកពេលឱ្យបានគ្រប់គ្រាន់សម្រាប់ការពិភាក្សាគ្នារវាងវាគ្មិន និងអ្នកចូលរួម។




រូបភាពទី ១៖ ការវាយតម្លៃលើការគ្រប់គ្រង និងការសម្របសម្រួលកម្មវិធី

ពាក់ព័ន្ធនឹងខ្លឹមសារជារួមរបស់កម្មវិធីនេះ អ្នកចូលរួមពេញចិត្តជាមួយនឹងកម្មវិធី។ ៩៣% ដាក់ពិន្ទុ 'ពេញចិត្ត' និង 'ពេញចិត្តខ្លាំង' និងបានលើកឡើងថា ប្រធានបទទាំងនេះពាក់ព័ន្ធខ្លាំងទៅនឹងបរិបទបច្ចុប្បន្ន ហើយវាគ្មិនសុទ្ធតែជាអ្នកដែលមានបទពិសោធន៍ និងមានចំណេះដឹងអំពីប្រធានបទទាំងនេះ ជាពិសេសមន្ត្រីរដ្ឋាភិបាលបានឆ្លើយតប និងចូលរួមយ៉ាងសកម្មនៅក្នុងការពិភាក្សា។ ប៉ុន្តែ មានការផ្ដល់នូវមតិត្រឡប់ អំពីការរៀបចំជា ៣ បន្ទប់ ព្រោះថាអ្នកចូលរួមមួយចំនួនខកខានពុំបានចូលរួមស្ដាប់ប្រធានបទដែលគួរឱ្យចាប់អារម្មណ៍ និងមានការលើកជាសំណូមពរឱ្យមានការរៀបចំត្រឹមតែ ២ បន្ទប់ ដើម្បីងាយស្រួលគ្រប់គ្រងការចូលរួមក្នុងការពិភាក្សាជាមួយវាគ្មិន។




រូបភាពទី ២៖ ការវាយតម្លៃលើខ្លឹមសារកម្មវិធី

នៅពេលសាកសួរពីរយៈពេលរបស់កម្មវិធីនេះ អ្នកចូលរួម ៦០% ចង់បាន ២ ថ្ងៃ និង ៣៥% នៅតែចង់បាន ១ ថ្ងៃ។




រូបភាពទី ៣៖ រយៈពេលដែលស្នើឡើងសម្រាប់កម្មវិធីបន្ទាប់

អ្នកចូលរួមបានលើកស្នើប្រធានបទខាងក្រោមសម្រាប់កម្មវិធីពិភាក្សានៅលើកក្រោយ៖

- ការគ្រប់គ្រងធនធានធម្មជាតិ៖ ការបាត់បង់ព្រៃឈើ និងការផ្លាស់ប្តូរការប្រើប្រាស់ដី
- ភាពធន់ទៅនឹងអាកាសធាតុ៖ យេនឌ័រ និងការប្រែប្រួលអាកាសធាតុ
- ប្រសិទ្ធភាពថាមពល៖ ឯកជនភាវូបនីយកម្ម
- សម្ភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI)៖ យេនឌ័រ ការអប់រំក្មេងស្រី ការផ្តល់សេវាសង្គម និងការអភិវឌ្ឍជំនាញដល់ជនមានពិការភាព ស្ត្រីក្នុងវិស័យទឹកស្អាត និងអនាម័យ
- ការរីករាលដាលជាសកល និងការវាយតម្លៃលើភាពងាយរងគ្រោះ
- ការចូលរួមរបស់យុវជន និងការងារសង្គម និងឧស្សាហកម្ម៤.០
- ការធ្វើចំណាកស្រុក ប្រកបដោយសុវត្ថិភាព
- និរន្តរភាពនៃមូលនិធិសោធន
- ការអប់រំស្តែម (STEM)
- កសិកម្ម និងខ្សែសង្វាក់តម្លៃ
- ការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម (ISAF)

# របៀបវារៈ

ការលើកកម្ពស់វិស័យសេវាសាធារណៈសម្រាប់ក្រុមងាយរងគ្រោះនៅកម្ពុជា

ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣
សណ្ឋាគារអង្គរប៉ារ៉ាឌី (Angkor Paradise) ក្រុងសៀមរាប ខេត្តសៀមរាប

| ម៉ោង | កម្មវិធី | ចំណាំ | បន្ទប់ |
|---|---|---|---|
| ៨.០០ ដល់ ៨.៣០ព្រឹក | ការចុះឈ្មោះ | ក្រុមការងារកម្មវិធីពន្លកចំណេះ | បន្ទប់៖ បាយ័ន |
| ៨.៣០ ដល់ ៨.៤៥ព្រឹក | ការបើកកម្មវិធី និងគោរពភ្លេងជាតិ | អ្នកកាន់កម្មវិធី (ពិធីករ) | បន្ទប់៖ បាយ័ន |
| ៨.៤៥ ដល់ ៩.០០ព្រឹក | សុន្ទរកថាបើកកម្មវិធី | លោក Andreas Zurbrugg<br>ឯកអគ្គរាជទូតរង<br>ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា | បន្ទប់៖ បាយ័ន |
| ៩.០០ ដល់ ៩.១៥ព្រឹក | សុន្ទរកថាគន្លឹះ | លោក ចឹង គឹមជុន នាយករង<br>រដ្ឋបាលសាលាខេត្តសៀមរាប | បន្ទប់៖ បាយ័ន |
| ៩.១៥ ដល់ ៩.៣០ព្រឹក | កម្មវិធីថតរូបជុំគ្នា | អ្នកចូលរួម | បន្ទប់៖ បាយ័ន |
| ១០.០០ ដល់ ១១.៣០ព្រឹក | **ការបើកកិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយស៖**<br><br>«ការលើកកម្ពស់ការផ្តល់សេវាសាធារណៈដើម្បីជួយគាំទ្រដល់ក្រុមងាយរងគ្រោះនៅថ្នាក់ក្រោមជាតិ»<br><br>សំណួរ និងចម្លើយ | វាគ្មិនកិត្តិយស៖<br>- លោក ចឹង គឹមជុន នាយករងរដ្ឋបាលសាលាខេត្តសៀមរាប<br>- លោក ប៊ឹង ពេជ្រ មន្ត្រីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តសៀមរាប<br>- លោកស្រី ចាន់ សុភា អ្នកគ្រប់គ្រងជាន់ខ្ពស់សម្រាប់ការចូលរួមសហគមន៍ នៃអង្គការទស្សនៈពិភពលោកអន្តរជាតិ | បន្ទប់៖ បាយ័ន |

| | | | |
|---|---|---|---|
| | | - លោកស្រី លី ផារ៉ុម អ្នកសម្របសម្រួលប្រចាំខេត្តសៀមរាប នៃអង្គការបន្ទាយស្រី<br>អ្នកសម្របសម្រួល៖<br>- លោកស្រី អេង ចាន់ឌី នាយិកាប្រតិបត្តិ នៃអង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា | |
| ១១.៣០ ដល់ ១.០០រសៀល | សម្រាកពិសារអាហារថ្ងៃត្រង់ | | |
| ១.០០ ដល់ ២.៣០រសៀល | **កិច្ចពិភាក្សាក្រោមប្រធានបទ៖ ក្រុមងាយរងគ្រោះនៅកម្ពុជា** | | |
| | **កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយស៖**<br>«ភាពធន់ និងការស្តារឡើងវិញ របស់បុគ្គលិកបម្រើការតាមសណ្ឋាគារនៅកម្ពុជា»<br>សំណួរ និងចម្លើយ | វាគ្មិនកិត្តិយស៖<br>- លោក ង៉ូវ សេងកាក់ ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប<br>- លោក ឌុច សារ៉េត អនុប្រធានសមាគមទេសចរណ៍កម្ពុជា<br>- អ្នកស្រីបណ្ឌិត អ៊ឹម សុខសម្ផស្ស អ្នកស្រាវជ្រាវ នៃមជ្ឈមណ្ឌលខេមរសិក្សា<br>អ្នកសម្របសម្រួល៖<br>- លោកបណ្ឌិត ជួន ទ្រី អ្នកស្រាវជ្រាវជាន់ខ្ពស់ នៃមជ្ឈមណ្ឌលខេមរសិក្សា | បន្ទប់៖ បាយ័ន |
| | **កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយស៖**<br>«ការស្វែងយល់អំពី សុខុមាលភាពសង្គម បណ្តាញសង្គម និងពលកម្មកុមារ ទាក់ទងការធ្វើចំណាកស្រុក ពីប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ ក្នុងបរិបទកូវីដ-១៩ »<br>សំណួរ និងចម្លើយ | វាគ្មិនកិត្តិយស៖<br>- លោកជំទាវ ប៉ុក ណាឌី អភិបាលរង ខេត្តពោធិ៍សាត់<br>- លោក អ៊ិន សុផល្លា អភិបាលរងនៃគណៈអភិបាលស្រុកកណ្តៀង ខេត្តពោធិ៍សាត់<br>- លោកស្រី ឡូវ សំណាន នាយិកាប្រតិបត្តិ នៃអង្គការអភិវឌ្ឍន៍នារីខ្មែរ | បន្ទប់៖ គូលែន |

| | | | |
|---|---|---|---|
| | | - លោក និល តំណាង អ្នកស្រាវជ្រាវ នៃមជ្ឈមណ្ឌលសម្រាប់ការវិភាគបញ្ហាអភិវឌ្ឍន៍<br>អ្នកសម្របសម្រួល៖<br>- លោក អៀ អ៊ីល នាយកប្រតិបត្តិ នៃមជ្ឈមណ្ឌលសម្រាប់ការវិភាគបញ្ហាអភិវឌ្ឍន៍ | |
| | **កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយស៖**<br><br>«ផលប៉ះពាល់ដោយជំងឺកូវីដ-១៩ លើការអប់រំរបស់ជនមានពិការភាពនៅកម្ពុជា»<br><br>សំណួរ និងចម្លើយ | វាគ្មិនកិត្តិយស៖<br>- លោកបណ្ឌិត ណុប កញ្ញារិទ្ធិ សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង<br>- លោក ទុន ប៊ុនតង នាយករង នៃវិទ្យាល័យអប់រំពិសេសសៀមរាប<br>- កញ្ញា សៀម ណារី សាស្ត្រាចារ្យ នៃវិទ្យាល័យអប់រំពិសេសសៀមរាប<br>អ្នកសម្របសម្រួល៖<br>- លោក គីម វ៉ារ៉ា នាយកនៃវិទ្យាស្ថានសិក្សាស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង | បន្ទប់៖ ខូហ្វី |
| ២.៣០ ដល់ ៣.០០រសៀល | សម្រាកពិសារអាហារសម្រន់ | | |
| ៣.០០ ដល់ ៤.៣០រសៀល | **កិច្ចពិភាក្សាក្រោមប្រធានបទ៖ វិស័យសេវាសាធារណៈនៅកម្ពុជា** | | |
| | **កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយស៖**<br><br>«គម្រោងប្រាក់សោធន៍និវត្តន៍សម្រាប់វិស័យឯកជននៅកម្ពុជា៖ ការត្រៀមខ្លួន និងផលប៉ះពាល់នៃសុខុមាលភាពសង្គម»<br><br>សំណួរ និងចម្លើយ | វាគ្មិនកិត្តិយស៖<br>- លោក ឈាវ ណារ៉ាត សមាជិកក្រុមប្រឹក្សាភិបាល នៃសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា<br>- លោក ឡេង សុខឡុង ទីប្រឹក្សា នៃនិយតករសន្តិសុខសង្គមកម្ពុជា | បន្ទប់៖ បាយ័ន |

| | | | |
|---|---|---|---|
| | | - កញ្ញា ប៉ូវ៉ា ស៊ុនហ្សូលីណែត អ្នកស្រាវជ្រាវ នៃមជ្ឈមណ្ឌលគោលនយោបាយ យុទ្ធសាស្ត្រ និងនវានុវត្តន៍<br>អ្នកសម្របសម្រួល៖<br>- លោកបណ្ឌិត អ៊ុំ សុធា នាយកប្រតិបត្តិ នៃមជ្ឈមណ្ឌលគោលនយោបាយយុទ្ធសាស្ត្រ និងនវានុវត្តន៍ | |
| | **កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយស៖**<br><br>«ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងវិស័យឯកជនក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា»<br><br>សំណួរ និងចម្លើយ | វាគ្មិនកិត្តិយស៖<br>- លោកស្រី គង់ ប៊ុណ្ណា អនុប្រធាន នាយកដ្ឋានវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)<br>- លោក លឹម មិញ នាយកប្រតិបត្តិ នៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា<br>- លោកបណ្ឌិត សៅ ដាវី នាយកប្រតិបត្តិ នៃអង្គការប្រើប្រាស់ទឹកប្រកបដោយចីរភាព<br>- អ្នកនាង ទីន ម៉ូឡា ប្រធានផ្នែកហេដ្ឋារចនាសម្ព័ន្ធ នៃកិច្ចសហប្រតិបត្តិការកម្ពុជា-អូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចធន់<br>អ្នកសម្របសម្រួល៖<br>- លោក ម៉ក់ សុខា អ្នកគ្រប់គ្រងកម្មវិធី នៃ WaterAid Cambodia | បន្ទប់៖ គូលែន |

| | | | |
|---|---|---|---|
| | **កិច្ចពិភាក្សាជាមួយវាគ្មិនកិត្តិយស៖**<br><br>«ការស្ម័គ្រចិត្តរបស់យុវជន អក្ខរកម្មផ្នែកឌីជីថល និងការអភិវឌ្ឍសហគមន៍៖ ករណីសិក្សាកម្មវិធីអ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំនៅកម្ពុជា និងផែនទីបង្ហាញផ្លូវសម្រាប់ក្រុមយុវវ័យ និងយុវជន»<br><br>សំណួរ និងចម្លើយ | វាគ្មិនកិត្តិយស៖<br>- លោក អ៊ុយ គា អនុប្រធាននាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល នៃក្រសួងអប់រំ យុវជន និងកីឡា<br>- លោក យ៉ាន ឡាយ នាយកប្រតិបត្តិនៃអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា<br>- កញ្ញា កៅ ម៉េងហ៉ង អ្នកស្ម័គ្រចិត្ត នៃកម្មវិធីស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ (កំពង់ចាម)<br>- លោក ពន់ គិរីក្រៃនេត្រ អ្នកស្ម័គ្រចិត្ត នៃកម្មវិធីស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ (មណ្ឌលគីរី)<br><br>អ្នកសម្របសម្រួល៖<br>- កញ្ញា ហួ បុផ្ផា មន្ត្រីគម្រោងនៃអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា | បន្ទប់៖ ខូហ្វី |
| ៤.៤៥ ដល់ ៥.០០ល្ងាច | សុន្ទរកថាបិទកម្មវិធី | លោកស្រីមេឡូឌី លីនបឹក តំណាងប្រចាំប្រទេស នៃអង្គការមូលនិធិអាស៊ី | បន្ទប់៖ បាយ័ន |
| ៥.០០ល្ងាច | បិទកម្មវិធី | | |




KNOWLEDGE EXCHANGE AND DIALOGUE
2023
Opening Plenary Discussion
Enhancing Public Service Delivery in Supporting Vulnerable Groups at Sub-National Level
Australian Aid
The Asia Foundation
Ponlok Chomnes Knowledge Exchange and Dialogue
"Enhancing Public Service Sector for Vulnerable Groups in Cambodia"
ADIC
CSIP

កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា គឺជាកម្មវិធីមួយមានរយៈពេលបួនឆ្នាំ ដែលផ្តួចផ្តើមឡើងដោយអង្គការមូលនិធិអាស៊ី ក្នុងគោលបំណងរួមចំណែកពង្រឹងសមត្ថភាពស្ថាប័នស្រាវជ្រាវ ដើម្បីលើកកម្ពស់ការស្រាវជ្រាវ ប្រកបដោយគុណភាព ដែលអាចប្រើប្រាស់ជាទិន្នន័យគាំទ្រដល់ការវិភាគ និងការពិភាក្សាអំពីគោលនយោបាយសាធារណៈនៅកម្ពុជា ក្រោមការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី។


**អង្គការមូលនិធិអាស៊ី**

ផ្ទះលេខ៥៩ ផ្លូវ២៤២ ខណ្ឌដូនពេញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ponlokchomnes@asiafoundation.org

(+៨៥៥) ០២៣ ២១០ ៤៣១

https://policypulse.org/


Australian Aid　ពន្លកចំណេះ　The Asia Foundation